គណៈកម្មការទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES
បណ្ណាល័យ LIBRARY BUDDHIST INSTITUTE
០៧

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូសុវណ្ណញាណ ស៊ូរ-ហាយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

### ផ្នែកអក្សរសាស្ត្រ

លោក ហេង-យ៉ាន់ . . . . . . កំពូលស្នេហា (រឿងប្រលោមលោក) . . . . . ១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ឯកសហស្សរាត្រី . . . . . . . . . . . . ១៦
ឧកញ្ញា ទេពពិទូរ-ក្រសេម . . . ប្រវត្តិស្តេចទឹកស្តេចភ្លើង (តមកនិងចប់) . . . ២៣
" " " វណ្ណគតិ នារាយណ៍ ទសាវតារ (តមកនិងចប់) ៣៨

### ផ្នែកសាសនា

យុគសុវត្ថិវេទី យូរ-អ៊ុន . . . . មិច្ឆាទិដ្ឋិកថា . . . . . . . . . . . . . ៤៩

ឆ្នាំទី ១៨ – លេខ ១ ខែយ៉ាំងវីយេ ១៩៤៦ – ដំឡៃជាវ : ១ ឆ្នាំ ៣៥ រៀល ។

# កាំភ្លុស្នេហា

លោក ហេង-យ៉ាន់ ប្រែប្រួល

## វគ្គទី ១

# បុរសកំសត់ម្នាក់

ព្រះអាទិត្យជ្រៀងជ្រេទោរទ្រៀងៗ ទៅទិសបស្ចិម ទៀបហៀបនឹង ចុះផុតព្រៃទៅហើយ មានខ្យល់រំភើយៗ ផាយផាត់ទឹក ទន្លេតូចល្អាញ ស្រស្រាញ់តាមក្រោមស្ពានមួយ នៅចុងមាត់ញកខែក្រុងព្រៃនគរ ទីនោះ ស្ងាត់ឈឹងស្ងប់ឥតមនុស្សម្នាដើរម្នាក់ មើលទៅខាងមុខឃើញតែវាលស្រែ ដ៏ក្រៀមក្រោះវាលល្វឹង ខាងម្ខាងសុទ្ធតែព្រៃល្បោះជាទីអាស្រ័យនៅនៃ បក្សីជាតិផ្សេងៗ ដែលពេលសំឡេងស្ទូចកេះគួរឲ្យរន្ធត់ ។

នៅលើស្ពាននោះ មានកុមារម្នាក់ស្លៀកពាក់ខោអាវចាស់ពក ណាស់ គឺខោខ្លីកញ្ចាស់មួយទីងអាវទ្រនាប់ឡើងខៀក ឈរសញ្ជប់ សញ្ជឹងនៅតែមួយពនៃឯងតណ្ហែងករណ្តាបយ៉ាងស្រងូតស្រងាត់ ដៃទាំង ពីរច្រត់លើបង្កាន់ដៃស្ពាន ហាក់ដូចមើលទឹកហូរស្រៀមទៅឆ្ងាយ កុមារនោះមានកាយតូចស្តើងសម្បុរសស្អាត ប៉ុន្តែជាទឹកមុខស្រពោន ស្រពន់ពុំស្រស់ដូចម្តេចក៏ គន់មើលលក្ខណៈឲ្យច្បាស់ទៅក៏ឃើញថា ជាអ្នកមិនធ្លាប់ទៀតប្រឡូកព្រោយលំបាកពីដើមមកឡើយ មុខស្រួន ច្រមុះ ស្រួចហាក់ជាអ្នកដេះកោតគួរ បបូរមាត់ក្រាស់កងកាច់ផ្ទុន ឯភ្នែកនោះជ្រៅ

ជួបអណ្ដូងខ្ចប់កូលះទៅក្នុង ព្រោះឥតទឹកដោះជាច្រើនឆ្នាំមកហើយ មាន
កម្ពេះ ដែលបាញ់ទៀងលើធ្មេញសំរស់ទៀង ច្រមុះនិស្រួចង្កូច បញ្ចូ
ពាក់ស្បៀងជាអ្នកជានសំដី ម្ដាមធំជាលក្ខណៈអ្នកមានបុនដានស្តុកស្ដុក
កនិងកុំមានទោសកាពេលមក្នុណាប់ ច្បាស់ជាកូនអ្នកមានត្រកូល
ភ្ជង់ខ្ពស់ ។

បន្ទរៗ លោកក៏ក្រឡេកជាង្ហើមដំម្ដងៗ រួចនិងដូចជាចង់សោយទុក្ខឲ្យ
ខ្ទាក់ចេញពីដើមទ្រូង និកណាស់ណាស់ទៅមិនដាច់ស្រេចក្នុងចិត្ត
កុមារនោះសំឡឹងមើលចិញ្ចៀនត្បូងក្រណ្ដៀង ដែលពាក់ទឹងដៃយ៉ាង
លោកប្តូរ ព្រោះចង់យកចិញ្ចៀននោះទៅលក់ដើម្បីបានលុយចាននក្រាន
ទង់កិច្ចការម៉ែតែទៅមុខទៀត ឯនោះក៏ឃាត់ខ្ទាំង តែទឹកស្ទាយរកតែនជាន
ពេលស់ខ្វះតុរេក ។

ឈ្មោះឡាយ ដែលកុមារនោះចំបងនិងទឹកតិតខ្ទង់ស្បូវលេកៈបាតលើ
ប្រាំ ម៉ាឲ្យកុមារនោះទឹកតិកក្រឡក់ព្រោះភ្ញាក់ដែលចំបងនិងដាក់ជល់
ខ្នងៗ ។

ឯការកែភ្ជក់កន្ទុះទៀងច្បាស់ដល់ទេនោះគត់ ចំដូចជាស្រមោលនៃ
កាពយន្ត ស្រមៃឃើញកញ្ចុំលុំមួយដែលលៃអណ្ដាតកណ្ដាលសមុទ្រ
ក្រោមមេឃជូរផង់ព្រួសតាកម្ទុល ។ នៅលើកបៀងកញ្ចុំលុំនោះ

អ្នកផងយកសារមើរជែរជាសរាយលេងកំសាន្ត ខ្ញុំចាំរតេខ្លួនប្រាណលើ កៅអីសំពត់មើលសៀវភៅ ខ្ញុំទំលាយភ្នែកគ្នារង្វើរបក្តោរគ្នាដើរចុះឡើង ៗ ។ នៅឯក្បាលតុបាល់ ប្រុសទីនស្រីកក្តាលអាយុ ២ នាក់កំពុងប្រស្រ័យ លេងជាមួយទីនក្នុងកំឡោះ ៤ នាក់ ក្នុងពៅអាយុប្រហែល ១៨ ឆ្នាំគឺកុមារ កំសត់នោះឯង ។

“មើចទៅកូន ឯងបាត់លើពោះហើយឬអី? ពាក់អាវកន្ទ ១ ជាន់ ទៀតទៅ កុំឲ្យវាត្រជាក់ដើមទ្រូងពេក” ។

“កូនជាហើយម៉ាក់, លោកគ្រូញញឹមរកមាតា - ម៉ាក់កុំព្រួយអី អាកាសសប្បាយណាស់ថ្ងៃនេះ ផកដង្ហើមចេញចូលជាសុខស្រួលក្រៃ លែង ម៉ាក់មើលហ្ន៎! ត្រីកចេះហើរបោកពីនេះទៅនោះដូចជាសត្វស្លាប គេនិយាយប្រាប់ខ្ញុំៗ មិនជឿ ឥឡូវឃើញច្បាស់នឹងភ្នែក” ។

“ពពកស្រាត់មកហើយកូន ឯងល្មមចូលទៅកន្ទបខ្ទប់ទៅក្រែងមិន ស្រួលខ្លួន” ។

លោកគ្រូចាប់ដឹងឈានជើងដើរកាត់ពីរពីជំហាន ស្រាប់តែមេឃ ងងឹតមួយរំពេចខ្យល់កំបុតត្បូងបក់ពីសព្វទិសាខ្លាំងសណ្ឋរចុះ កូចថ្មី សមុទ្រឲ្យញាប់ញ័រគេក្រោកកើតជារលកធំៗ ប៉ុនភ្នំ គេត្រងត្រាំងខ្ពស់ នាំតែកជាផ្កាក្រង ខ្ទក់ខ្ទល់រលរលំចុះឡើងដោយល្បឿនយ៉ាងលឿន អស្ចារ្យ វែកពពុះត្រាសួរឲ្យទឹកស្ទើរមពាន់ប្រមាណ រលកបោលមកលើ

គល្លាល់ដែលឃ្លេះឃ្លោងជ្រមុជជ្រមុល ស្ទើរតែនឹងកប់បាត់ក្នុងរលកសំទឹក ទៀវវិញ មានលំអងទឹកសាបធារ ៗ មកដូចគ្រាប់ភ្លៀង ឱមហាភ័យ! ផ្ទៃលៃព្រលប់ព្រឹកព្រាង អ្នកដំណើរស្ទុះចូលបន្ទប់ខ្លួនយ៉ាងស្រួលរួស យ៉ាង សែនសុភាពស្ងួតពិត ។

សំឡឹងមើលតាមរន្ធកញ្ចក់បង្អួចមូលទៅ ឃើញពពកលឿនស្ទើរ ប្រមូលបញ្ចូលគ្នាជាដុំធំ ៗ ជាលព្រាក់ភ្នាត់ខ្មៅនាំពេញផ្ទៃមេឃ ផ្គរបន្ទោរ ក្តីព្រលៗ ឲ្យមើលឃើញសភាពគួរស្ញប់ស្ញែងនៃមហាសមុទ្រ ខ្ទះអស់រ័ បោះទឹកកន្ត្រាំពង្ហួន ៗ គ្នា ម្ញាញ់ផាំង ៗ ខ្លះក្អាកក្អក វិស័យដូចលំ លោយភ្នំភពក្រពើ ។ សត្វកញ្ជ្រោងពេញមាហោកញ្ជ្រៀវគេក្រើកគគ្រេង កំរាក់ ទឹងស្លូវលោកបោលពេញផ្ទៃសាគរ រកគេពិតអ្នកជិះឲ្យព្រួញខ្លួន ប្រមដៃជាំងគូជាប់ក្នុងមុខស្ញើតស្ញាំង ។

ក្នុងខណៈនោះ មាតាហ៍តារសោកក្រសួះទៅប្រាប់ឪបពុត្រសំឡាញ់ ជាំពីតាខ្សែកខ្សែរកិច ៗ ហើយខ្សឹបដាក់ត្រចៀកដោះជ្រៀនជងថា "កូន អើយ ... បើកម្ទេចជា ...... ទឹងវៃកត្រាត្រាំឱះឯង ..... ណើយ កូនប្រុះ ...... កុំគក់ស្ទត ............ នឹងមក្លាជដែលតំកមចូល មកកា តែជិតជល់រូបហើយទាំង ៤ នាក់ ចូរកូនចាំពាក្យម្តាយមួយម៉ាត់ ទិកុំបះបេដិកាតោងណាព្រះគេនត្រៃយថ្ងៃគួរ ។

នាពេលជាអនេកវេទនានេះ អ្នកទាំងអស់គ្នាក្រពះបក្ខមិនកើត រកជួរត្រញ្ញែរថ្ងៃនឹងទុក្ខសុខមិនបាន ត្រាតែព្រះពុទ្ធព្រាណាដោយមេសញ្ញា-ជាតិបង្គាប់ប៉ុណ្ណោះ ស្រឡាំងកាំងកន្ទក់កាំងស្មារតី ហាក់ដូចជាព្រាសចាកវិញ្ញាណគេនឹងគាន តាមដំណាំរណគអំណាចភ្លៀងខ្យល់គ្របសង្កត់សង្កិនជុំវិញ ណាស្រូវសំឡេងខ្ទរស្រែកត្រចៀកនៅទាំងភ្លួងធំ ដែលទ្រហឹងជាសញ្ញាថា មានគ្រោះថ្នាក់ធ្លាក់លើនាវានាកណ្តាលសមុទ្រធំមេងទីងស្រូវកញ្ចែះផ្ទួក ៗ បង្គាប់ឲ្យពួកនាវិកៈទំព្រើនប្រែងកៃវ ឲ្យស្រុកអំពីអន្តរាយទ្រហឹងអឺង ៗ មិនចេះអស់ ។

រលកធំៗបោកផ្លុបមកជាច្រើនលើកច្រើនគ្រា ទុកជាពួកនាវិកៈប៉ុនប្រាំអោកដងទឹកយ៉ាងពុំណាខដូរៈមុបក្តី កប៉ាល់ក៏មិនអាចនឹងទ្រាំទល់ផល់សេនាព្រះពាយុបុត្របាន ក៏ដល់ទូកាគាប្រេះធ្លាយមួយរំពេចទៅ ។ សម្រែកជាទុក្ខសុះចេញពីមាត់ពប់យេ ទឹកក្លួកហូរហោយលើមុខស្រស្ទូប-ស្រសាក់ អ្នកដោយសារកើតភ័យព្រួលព្រប់ល់រង្គើ បងប្អូនបែកគ្នាទៅម្នាក់ម្នាក់ ចំណែកលោកគ្រូក៏ស្រឡាំងកាំងកាត់កាំងស្មារតី មួយសន្ទុះបាត់ដឹងខ្លួន ព្រោះតែរកពុកក្មាយចិនបងប្រុសមិនឃើញខ្លួន ។

នៅពេលនោះ គេបានទម្លាក់សំប៉ាន់ពីរទៅក្នុងទឹក បម្រុងអ្នកជិះជួយឲ្យផុតអំពីសេចក្តីភ័យអន្តរាយ ចំណែកអ្នកដែលបុនហែល ក៏លោក

ចុះទឹកយកតែកាយខ្លួនមួយ ទៅសល់តែខ្លួន ១ នាក់ប៉ុណ្ណោះនៅលើកប៉ាល់ ។

ទឹកចូលតាមកន្ទ្រាន់តែច្រើនណាស់ហើយ សេចក្ដីសង្ឃឹមគង់មានគេមកជួយនោះក៏រលាយតាមទឹកទៅ ដូចជាលោកបោះដុំបាតមក កប៉ាល់ក៏លិចសស្រឹមសន្សឹមៗ ទៅ ។

លោកគ្រូចាប់បានគល់ឈើ ១ កំណាត់ តោងហែលកាត់រលក បណ្ដែតខ្លួនទៅ តែមហាសមុទ្រសន្ធឹកធ្លាយទូលាយក្រៃលែង រកមើលនោះត្រើយក៏ពុំឃើញផង ហើយលោកគ្រូហែលរកដីកំណត់ ១ ទៅងលៀនទៅមុខបានប្រហែលជាពីរម៉ែត្រប៉ុណ្ណោះ ព្រោះបានទៅគ្រឿន ទៅមុខហើយរលកច្រានថយមកក្រោយវិញ លោកគ្រូអស់កម្លាំងខ្លាំងណាស់ ទំតោងគល់ឈើឲ្យខ្ជាប់ហើយបណ្ដោយឲ្យវាអណ្ដែតយោគយោលតោលទៅតាមខ្យល់និងរលក ចួនជាពេលបញ្ចូលយប់ខ្យល់រលកដែលបោកមកកន្ទ្រប់គ្នា ក៏បង្កើតជាផ្កាភ្លើង ភ្លឺព្រោងព្រាតសន្សោសន្សៅ វិស័យដូចជាតន្ត្រីព្រាយយោះ ។

លោកគ្រូនឹកខ្លាចមហិមា ណាទឹកភ័យខ្លាចគេញញាណព្រាម បករដី ធ្វើចេញពីភាវនា "អរហំ ៗ" តាំងស្មារតីជានិច្ច តាលតែ ស្រែកៗកជនការតែទៅ ។

លុះដល់អរុណរះភ្លឺច្បាស់ឯបុព្វទិស  សោភ័ក្ត្រភ្ញាក់ខ្លួនបើកបង្អួច មើលស្រាប់តែឃើញខ្លួនថា ដេកកើយលើថ្មខាងឆ្នេរសមុទ្រមាត់កោះតូចមួយ ក្រោកងើបឡើងអង្គុយ ដល់រកមើលគេឯងមិនឃើញ ទឹកដីមានដល់ត្រោះ ថ្មក៏ពីថ្ងៃម្សិលមានច្បាស់លាស់  សោភ័ក្ត្រក៏ដើរមុជទៅកម្លាំងរំពេច មានទឹកភ្នែកហូរស្រក់ចុះមក  ឲ្យភ្នែកសោភ័ក្ត្រហាក់ដូចជាមានដែក ដុតក្រហមកេះចាក់ហើយហ្ន៎! ដើមទ្រូងដែលសម្បូរណ៍ទៅដោយស្នេហ៍នេះប្រែ ក្លាយជាប្រេះឆា ទើបទន្ទឹះខ្សឹកខ្សួលឡើងថា ៖

"ឱ! ទានមណីមេខលា ទេពធីតារក្សាមហាសមុទ្រ! ម្ដេចមកពង្រាត់ យើងឲ្យប្រាសចាកគ្នាយ៉ាងនេះ បងអូន បើបានជាគេមកឲ្យវេទនាហើយ ដោយហេតុអ្វីក៏មិនយកខ្ញុំទៅផង? ទុកខ្ញុំឲ្យរងទុក្ខវេទនាសព្វបែបអ្វី? ខ្ញុំសុខ សង្ឃឹមហើយ ខ្ញុំមិនចង់រស់នៅតទៅទៀតទេ ពីព្រោះតាំងពីពេលនេះមក ខ្ញុំ មិនដែលឃ្លាតឆ្ងាយពីញាតិមិត្តជាទីស្រឡាញ់នោះ ឥឡូវនេះនៅតែឯង កណ្ដាលសមុទ្រ ពកណ្ដាលទឹកដូច្នេះ គួរឲ្យតក់ស្លុត! ឱ! ទេវតាអើយ! ជួយជីវិត ខ្ញុំមិនរស់នៅទេ! ។

តពីនោះមក សោភ័ក្ត្រក៏ចាប់ផ្ដើមទុក្ខសោកស្រណោះជាអនេកប្បការ យ៉ាង ទៀតណាយទៀតនឹងចង់ក្រាបទៅទីណាទៀត ព្រមសុខចិត្តយក កោះនោះជាសាក្សីនៃពេលជាន់ក្រោយបំផុតរបស់ខ្លួន តែប៉ុនជាត្រឡប់ មើលទៅ ឃើញទឹកសមុទ្រខៀវខ្ចីលំបីដូចប្រេង ឃើញអាកាស

ត្រជាក់ស្រួល មេឃក៏ស្រឡះផូរផង់ ទើបលោកគ្រូមែតគំនិតជាថ្មីឡើង ទៀតថា :

"មហាសមុទ្រដែលមានសភាពគួរស្ញើមកាលពីម្សិលនោះ ព្រោះខាងព្យុះព្យាមា តែឥឡូវបែរជាមានសំរស់គួរឲ្យស្រឡាញ់យ៉ាងណាមិញ រីឯជីវិតរបស់មនុស្សក៏យ៉ាងនោះដែរ តែមានសុខហើយតែងមានទុក្ខ ផ្លាស់ប្តូរគ្នាជានិច្ច ថ្ងៃនេះមានទុក្ខ ថ្ងៃក្រោយគង់ជួបប្រទះនឹងសេចក្តីសុខ មិនខានឡើយ បើដូច្នោះគួរតែអញចិញ្ចឹមសេចក្តីសង្ឃឹមជានិច្ចក្នុងដួងចិត្តទៅ ប្រហែលជាអ្នកដែលមានគុណតាំងពីទើបនឹងប្រុសរបស់អញនៅរស់កំពុងមានជីវិតនៅឡើយទេដឹង? គួរតែខំប្រឹងស្វែងរក តែដឹងជានៅទីណាទេះ បើសុទ្ធតែទឹកដូច្នោះ" ។

ទើបលោកគ្រូក្រោកចាកទីនោះ មានតែកាតា ១ ចង្កេះជាប់នឹងខ្លួន យកដៃស្ទាបហោប៉ៅក្រោយប្រទះនឹងក្រូបលុយ ដែលជាប់នឹងខ្សែរ មិនបាត់វិនាសទៅក្នុងទឹក ទាញយកមកបើកមើលឃើញមានសល់ក្រដាស ២០,០០ មួយសន្លឹក ទឹកសព្រមក៏ដើរលេងលើកោះតូចនោះ ៗ ថ្ងៃនិតក្រន់ដោយអស់កម្លាំងខ្លាំង ណាអត់បាយ ១ ថ្ងៃ ១ យប់មក លោកគ្រូញ័រជើងដើរទៅទៀតពុំរួចក៏ដួលចុះលើខ្សាច់ បើកភ្នែកក្រៃមើលអ្វីក៏ឃើញព្រិល ៗ ទើបសន្លប់បាត់មាត់ទៅ ៗ ចួនជាពេលនោះ

មានអ្នកនេសាទត្រីពីរនាក់បរទូកមកដល់កោះនោះ បានឃើញកុមារកំសត់នេះនាំគ្នាជួយរែកគ្រូសរសៃទាល់តែបានដឹងខ្លួនឡើង ទើបគេឲ្យអាហារបន្តិចបន្តួចស្រែស មានកំលាំងកំហែងហើយសោភ័ក្ត្រក៏ថ្លែងរឿងខ្លួនប្រាប់អ្នកស្ទូចត្រីសព្វគ្រប់ ព្រានសន្ទូចនឹកអាណិតណាស់ព្រមឲ្យដោយសារទឹងទូកគេទៅ ដល់កណ្ដាលផ្លូវបានជួបកប៉ាល់ ១ ទើបហៅកប៉ាល់នោះឲ្យឈប់យកមនុស្ស កប៉ាល់នោះក៏ឈប់តាមពាក្យអង្វរ សោភ័ក្ត្រត្រេកអរផតគុណនា និយាយលាអ្នកនេសាទត្រីឡើងជិះកប៉ាល់ ហើយបានទិញអាវខោនាប់ ១ ពាក់បង្ការកុំឲ្យរងាពេក ។ បំនួន ២ ថ្ងៃក្រោយមក សោភ័ក្ត្របានដល់ក្រុងព្រែនគរ ចុះដើរលេងតាមភូមិប្រទេស គេឃើញមានផ្ទះធំ ១ ផ្លូវវែងទូលាយដូច ។ គ្មានគេស្គាល់មិនបានវង្វេងវិលមុខសោភ័ក្ត្រក៏ដើរទៅឈរលេងលើស្ពានខ្ទុះឯង ៕

យូរបន្តិចលេចអាចារ្យបារ៉ែនបើករថយន្តមកដល់ទីនោះហើយបញ្ឈប់រថយន្តហៅសោភ័ក្ត្រឲ្យឡើងជិះ រួចបើកចេញពីទីនោះទៅមួយរំពេច ។ ឯសោភ័ក្ត្រមានសេចក្ដីត្រេកអរក្រៃពេក ដោយមានសង្ឃឹមនាំក្នុងចិត្តថាម្ដងជាមិនអត់បាយស្លាប់នៅស្រុកគេ ហើយម្ដងជានឹងបានទៅដល់មាតុភូមិជាប្រាកដ ។

*

* *

## វគ្គទី ២

# សោភ័ក្រ្តពេនធូរទ្រឹងពន្ធ

វេយន្តបរកាត់ផ្លូវគេលកុងជាលំដាប់ជ្រុមទំ ៧ហោរទៀត ងដើង វេយមានក្តីទៀតស្ទើង ។ ហាក់ដូចជាវិលជុំវិញខ្លួន នៅសងខាងមាត់ មានសត្វក្របីឈ្មោះ ញាំកំពុងតែស៊ីស្មៅ ពួស្មូរមាស៊ុនទ្រហ៊ឹងមកជិត ក៏ស្ទើងក្តែកងើបហើយមើល ៗ ប៉ុន្តែសោភ័ក្រ្តមិនបានអើពើមើលភូមិស្ថាន ទាំគួរលតារល្មិទេ វេលតែឈ្ងុំកផ្តេញគិតគិតដល់ជោគវាសនារបស់ខ្លួន ព្រោះនឹកឃើញថា ""ប៉ុក្ដិតែបានអាពាហ៍ពិពាហ៍ស្រីនោះ ប្រហែលជា ដាច់ពោះកណ្តាលស្រុកគេទៅហើយ នេះហេតុតែកំសនាទៅមាន ទើប បានមកអង្គុយជាសុខលើតួកខ្លួននេះ ខ្ញុំឲ្យប្រកែតដល់មាតាបិតានឹងបង ប្រុសអ្នកម្តាយ! តាក់ នាំឡូវជីវិតរស់នៅទៀយទេ ឬ មួយក៏អនិច្ចធម្មបាត់ បង់ទៅហើយអេះ? ដល់ត្រង់នេះមុខសោភ័ក្រ្តក៏ស្រពោនចុះក្រោម ទឹកភ្នែក ហោមជោគមុខមួយរំពេច ទើបតេវហែរនេះខាត់កុំឲ្យអាចារ្យជំង ។

ឧត្តមស៊ីមិនស្មើខ្លួនបែប ប៉ុន្តែដែលព្រាសចាកអាតាបិតា កាលវ័យខ្លួន នៅក្មេងនៅឡើយ ព្រោះមាតាបិតាដូចជាអ្នកកាប់ចង្កត់ណានាំឲ្យ ព្រៀងលយ ត្រង់ទៅតាមផលបុណ្យ ព្រះវិញញ្ញាចិត្ត កាលបើអត់អំពីអ្នក កាប់ចង្កូតទៅហើយ កាលណាឡើយបាក់បាល់ទឹងបើកត្រង់បាន មុខជា ទឹងវិលវល់ខ្ចាក់ខ្ទល់លែងស្គាល់ទិសតំបន់ ។ ដោយហេតុនេះ សោភ័ក្រ្ត

ហាក់ដូចជាកន្លែងឯកឯងដាច់ពីពិភពលោក ហើយក្រោមអគារនោះគេទំពាំង ពាំនាំគ្នា ទុកជាបានការប្រជុំយកទុកបំរុងដូចស្ដេចក្ដី ក៏គង់តែដូចជា គុកក្រាន់ដាក់សេចក្ដីអ៊ូ ដែលជាទ្រាក់ហាននៃសេចក្ដីទុកចិត្តស្មោះស្ម័គ្រ ផល់ដោយកក់សនា ព្រោះមាតាបិតាមិននៅជិតហើយភ្លើងជីវិតក៏ដូច ចាំសាបសូន្យទៅដែរ ។ តែសោភ័ក្រ្តនៅសង្ឃឹមថាទុកជាយ៉ាងណា អ្នកដ៏មានគុណទាំងពីរគង់មានជីវិតរស់នៅឡើយ ព្រោះមិនសមបើមក ឃ្លាតឆ្ងាយលែងឃើញមុខសោះ ពីរពាក្យម្ដាយនោះនៅជួបជុំគ្នាទេតើ ម្ដេច ក៏ថាបាត់ សោភ័ក្រ្តមិនសុខចិត្តទេ ចុះបានអ្វីជាទីអាង? មានតែសេចក្ដី សង្ឃឹមយ៉ាងមាំមួនប៉ុណ្ណោះ ដែលនាំឲ្យសោភ័ក្រ្តទឹកអព្រួច ចង់ឲ្យ ដល់ដំណាក់ឆាប់ៗ ទីងអាណាក់យកទូរលេខមួយច្បាប់ផ្ញើទៅបួរ ដំណឹង អ្នកទាំង ៣ ៦ ស្រុកឯណោះ ទើបងើបមុខធាលក្រែកតយគន់មើលធម្ម-ជាតិផ្សេងៗ ។

ស្រាប់តែដឹងខ្លួនថាឡើងលើកំពូលអាកាសទៀតម្ដង គាត់ធ្ងុំ ឃើញការពួក មនុស្សម្នាសខ្លួនទទេ ពាក់មួកចបូត តែប្រាំងបើមិនបានឃើញពាហាន ស្ពាយកាំភ្លើងឈរព្រួតគ្រាទេ គេទឹកស្មានថាជាអ្នកស៊ីឈ្នួលរបម្នា កំពង់លើតបបងដៃពីរគាប់ជុំជុំៗ ហូរញើសជាថ្លង់ ។ សំឡឹងទៅលើ ឃើញកេះជនាគារតូចមួយ ខ្ពស់ត្រដឹមគណ្ដា ឬដើមឈើស្រោងស្រងាត់

វិស័យដូចបុកណាផ្ទានគេបោះបង់ចោលនៅទីនោះ ឲ្យវល្លិ៍ជាតិនានារុំ ករុំខ្ទានព័ទ្ធព័ទ្ធជុំជាស ធ្វើឲ្យអ្នកដំណើរកើតបញ្ហាកំបាំងក្នុងចិត្ត ជំនិត ។

លុះថ្ងៃមេឃបើកដល់លើភ្នំ កំពូលព្រៃស្រស់ត្រសំហៃដែលឲ្យដឹងថា ទីនោះមានជីវិតដែកត្បូងបម្រុងទៅ. ក៏តែងដូកម្រាស់ ១ ម៉ែត្រឡើងក្រមៅ ព្រោះស្លុកកាប់ស្រស់បំព្រងដោយអន្ទើងដ ព្រោះឫកឈើត្រូវបំបាំង សង់ជាក្រោងក្ដារមៅសំបើមតាពោះទឹកខ្ទង់ព្រៃទាំងអាំក្បែងធំពីរ ប្រែះ ផាប់កប៉ាត់ទៅក្នុងដី ក្រឡេកមើលទៅក្នុង ឃើញបន្ទប់ផេកព្រៃធំល្វែង លយវែងតាំងលិច ជាប់តទៅដល់ទីអន្ធពេលងក់សារដ្ឋយកខ្យល់ អាកាស, ឯខាងកើតគឺផ្ទះបុរាណ ទៀបកាយនៅខាងស្ដាំដៃ មានបន្ទប់ផេក ១ ល្វែងទៀតនៅបំពុំ។ ខាងក្នុងដៃគឺបន្ទប់សម្រាប់សំចតទុកខ្លួន បន្ទប់ ទាំងអស់នោះសុទ្ធសឹងធ្វើអំពីឥដ្ឋ ជញ្ជាំងកណ្ដាលពលល្វឹងត្រឈើត្រឡៃ ប្រកបដោយដើមឈើធំៗ ចោលម្ហូបត្រជាក់ ប៉ុន្តែស្លាកជៀបជតព្រះស្អី ក្រៅពីស្មុះស្លឹកឈើបក់រវិច ។ ហាក់ដូចជានៅកណ្ដាលទីសា ស្រមមួស៊ីអគ្គ ណាមួយ ។

លុះឡានចូលដល់ខាងក្នុង ស្នូរមាស៊ីនប្រកាសប្រាប់ថាមានអ្នកដំណើរ មកដល់ ទើបលេចម្ចាស់គេជនានារម្នាក់មក អ្នកនោះឯងចាស់ជរាហើយ

សក់ស្កូវសរសៃព្រះ អាចារ្យក៏បានបង្ហាន់បន្ទប់ពីរ ចុះឈ្មោះទីលំនៅ និង ក្រសួងត្រួតការ រួចបានទទួលឡានទុកដោយស្រួល ។

តមកអាចារ្យក៏នាំសោភ័ក្ត្រដើរទៅឈរលេងលើទីកន សំឡឹងមើលក្រោមឃើញជណ្ដើរចុះទៅមាត់សមុទ្រ ដេរដាសទៅដោយសត្វល្អិតខ្លួនក្រហមមុខខៀវតូចអន្ទ្រងវារវើកដោយអន្ទើរ ៗ កាំភ្លើងធំទើបមាត់ត្រូវបង្កិចចេញពីដីមកសឲ្យឃើញថា ទីនោះជាកាតបន្ទាយពីដើមរបស់យួន ឯនាយឯណោះសមុទ្រធំឆេងកន្លាញ់ដោយរលក ឯកោះទៀតស្ទួនៗ អណ្ដែតត្រសែតកណ្ដាលសរមៃយទឹងមក ។

សេចក្ដីស្ងាត់ជ្រងំនេះបេចក្ដីម្ចាស់កាយសប្បាយចិត្ត ព្រមទាំងខ្យល់អាកាសត្រជាក់ល្អ បញ្ញុនវិញ្ញាណរបស់អ្នកដំណើរឲ្យអណ្ដែតអណ្ដែងកងការស្រមៃ យើងយោងតាមបរដន្ទ្រីនៃរលកសមុទ្រ ដែលខ្យល់ផាត់ផាយនាំមកដល់ត្រចៀកលាន់រងំ គួរឲ្យស្ញប់ទឹកស្រពោះកាចផ្ទុះអាល័យនៃន ៗ លុះអាចារ្យចូលទៅផ្ទះសំរាកសំអិតសំ-អាងកាយ សោភ័ក្ត្រចាប់ក្រដាសនិងដរ៉ាក្កកា ធើបមុខចោលភ្នែកយកតន់មើលធម្មជាតិ ៗ ក៏ចាប់សរសេរឡើលេខ ១ ច្បាប់ក្លាម ផ្ញើទេឯឲ្យយកទៅឲ្យមន្ទីរប្រៃសណីយ៍ ហើយនៅនិងចាំសេចក្ដីតបទៅទីនោះព្រោះអាចារ្យមិនទាន់ដល់កំណត់ចូលធ្វើការនៅឡើយ នៅសម្រាកខ្លួនលើកូចំនួន ១ អាទិត្យទៀត ។

លុះដល់ថ្ងៃតាំងរបាំ ។ សោភ័ក្ត្រក៏ទៅលេងមាត់ទឹក គង្គុយលំហើយ ខ្ទមលើកោះសិរីជិតនៃកំពុះ ។ អាកាសពេលនោះត្រជាក់ស្រួលគន់ ពេក ដកដង្ហើមចូលទៅហាក់ដូចជាមានកំឡាំងពិសេស ឯលោកដែល ប្រែដេញតាមហាបលើផ្ទៃខ្សាច់ ហាក់ស្រួយស្រស់ល្អលើលើយ ទឹង ខ្យល់ត្រជាក់ ក៏កើយទឹងត្រចៀកសណ្តំវិញ្ញាណឲ្យទន់ចុះ នាំឲ្យកើត សេចក្តីសង្វេគ ។

ក្នុងខណៈនោះ ពួកស្រីដើរមនុស្សនៅតាមក្រោយខ្នងមក សោភ័ក្ត្រ ងើបឡើង ឃើញកូនកាត់ខ្ទង់ពីរសំពតពណ៌ខៀវសណ្ដាប់ធ្មេញជើងហុច ឲ្យពីចម្ងាយមក សោភ័ក្ត្រស្ទុះក្រោកចាកកៅអីទៅទទួល បានសំបុត្រ កាន់នៅដៃ ហើយវិលត្រឡប់មកគង្គុយកៅអីដដែលវិញ លើកសំបុត្រ ឡើងដាក់លើដើមទ្រូងដោយសេចក្តីគោរព តក់ស្លុតនឹកចិត្តមិនដឹង ក័យនឹង ញ័រដៃហែកសំបុត្រស្ទើរមិនចង់កើត ។

ខណៈដែលសោភ័ក្ត្រកំពុងមើលសំបុត្រ ចំពោះមកក៏ត្របាញ់ផ្កា ខ្លះ ខ្លួនទៅ ទ្រនុងត្រង់លើខ្លួនព្រមុះ មើលប្រែក្ដីបានបាត់កណ្ដាលក៏ បាត់ដៃម្នាក់ចុះដោយគុតសង្ឃឹម សំឡឹងមើលទៅឆ្ងាយចេញហើយស្រងូត ស្រងាត់ ស្ដាប់ទ្រព្យបានលើកសំបុត្រឡើងអានតទៅទៀត មុខក្រញ៉ូវ សង្រៀម ៗ រឹតចង្អិតម្តង ៗ ឡើងវិញ ចុងបំផុតបបូរមាត់ញញឹមយ៉ាង ស្រស់ ឯសំបុត្រនោះអានសេចក្តីដូច្នេះ :

អ្នកស្រុក . . . . ទៅថ្ងៃ ២ ម៉ាឃ ១៩២៩

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . កាលបើយើងបានដំណឹងមកថា មានព្រោះកប៉ាល់លិចកណ្ដាលសមុទ្រ យើងតែងតែមានទុក្ខព្រួយរៀងរាល់ថ្ងៃមិនដែលដាច់ ក្នុងបណ្ដាអ្នកស្រុកយើងដែលធ្វើដំណើរទៅនោះ ពុំមាននរណាគួលវិលមកឃើញផ្ទះសម្បែងវិញទេ តាំឡូមាតាយំសោកព្រោះស្លាយបុត្រ ញាតិមិត្តខ្សឹកខ្សួលរំជួលថ្លើមព្រោះឃ្លាតពាកបុគ្គលជាទីស្រឡាញ់ពេញចិត្ត ។ ប៉ុន្តែយើងទាំងអស់គ្នាមែងតប់ប្រមល់ ព្រោះនឹកដើមដល់ឪពុកម្ដាយរបស់ចៅដែលមានឧបការគុណលើយើងរាល់គ្នាជាច្រើន គួរឬមកខាតអ្នកចិត្តបុណ្យទៅដោយគិតស្រណោះយ៉ាងនេះ . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . ពីព្រឹកមិញ មាននាយនាវិកម្នាក់មកលេងនៅទីផ្សារបាននិយាយប្រាប់ថា អ្នកដែលលិចកប៉ាល់នោះ មានគេជួយស្រង់ជីវិតបានទាំងអស់ ពុំមានស្លាប់ទេ អ្នកដែលព្រាត់ប្រាសទៅមុខជានឹងបានត្រឡប់វិលមកវិញ ដោយហេតុនេះ យើងនឹកស្មានថា មាតាបិតានិងបងប្អូនរបស់ចៅ នង់នឹងបានមកឃើញមុខយើងរាល់គ្នា បានជាបាត់ដំណឹងប្រហែលអាស្រ័យដើរស៊ើបសួររកកូនឡាងផ្លូវជុំគ្នាទេដឹង បើដូច្នោះចៅកុំព្រួយចិត្តអ្វី ចាំដើរស៊ើបសួរទៅគង់នឹងប្រទះគ្នាពុំខាន . . . . . . . . ។

អ្នកស្រុក

គបទៅទៅសោកក្រៃ

ឯកសារសាស្ត្រកេរ្តិ៍

មួយពាន់មួយយប់ (ជារឿងភាគ)

ភាគទី១០

# ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ប្រែចេញពីភាសាបារាំងសែសមកជាខេមរភាសា

## រឿងអ្នកបួសទី ៣ ជារាជបុត្រស្តេច

សូមជំរាបអ្នកស្រី, រឿងរ៉ាវដែលខ្ញុំនឹងនិទានជូនអ្នកស្រីស្តាប់តទៅនេះជារឿងប្លែកផ្សេងគ្នាណាស់ អំពីរឿងដែលអ្នកស្រីទើបតែនឹងបានស្តាប់មកអម្បាញ់មិញនេះ ។ ព្រះអង្គម្ចាស់ទាំងពីរអង្គ ដែលបាននិទានរឿងមកមុនខ្ញុំនេះ ខ្វាក់ព្រះនេត្រម្ខាងដោយព្រោះកម្មរបស់ខ្លួនឯង ឯខាងខ្ញុំវិញមិនមែនដូច្នោះទេ គឺខ្ញុំខ្វាក់ភ្នែកម្ខាងដោយសារតែកំហុសរបស់ខ្ញុំ ដែលខ្ញុំរត់ទៅរកគ្រោះថ្នាក់ដោយខ្លួនឯង ដូចរឿងដែលខ្ញុំនិទានជូនអ្នកស្រីស្តាប់តទៅនេះ ។

ខ្ញុំឈ្មោះអាយ៉េប ជាព្រះរាជបុត្ររបស់ស្តេចសោយរាជ្យព្រះនាមកាស៊ីប លុះព្រះវររាជបិតាទិវង្គតទៅ ខ្ញុំក៏បានឡើងគ្រងរាជ្យជាតំណាងមក ហើយខ្ញុំក៏ស្ថិតនៅក្នុងក្រុងដដែលនុះឯង ។ ឯក្រុងនេះ នៅក្បែរមាត់សមុទ្រ ហើយនៅជាកំពង់យ៉ាងសុខស្រួល ១ សម្រាប់ចតនាវាចម្បាំងបានចំនួន ១៤០ ហើយខ្ញុំមាននាវាជំនួញដទៃផ្សេងៗទៀតចំនួន ៥០ គឺនាវា

ខ្នាតតូចសម្រាប់ប្រពាតជាយសមុទ្រ ក៏មានចំនួនប្រហែលគ្នាដែរ ។ ឯកជាទីខ្ញុំមានដើរគោកវិញ ក៏បានទៅក្រវ័ណ្ណពីស្រុកស្រួលជាច្រើន ព្រមទាំងកោះតូច-ធំនានា មានដើរទឹក ។

ដំបូង៖ ខ្ញុំចេញទៅក្រុងក្រៅខេត្តណាផ្សេងៗ មានដើរគោក រួចខ្ញុំឲ្យរៀបចំនាវចម្បាំង ហើយខ្ញុំក៏ចុះនាវចេញទៅក្រុងកោះផ្សេងៗ មានដើរទឹក ។ ក្រោយដែលបានក្រុងក្រៅអស់ ២-៣ វេលា ខ្ញុំក៏វិលត្រឡប់មកស្រុកវិញ ។ ប៉ុន្តែការធ្វើដំណើរតាមដើរទឹកគ្រានោះ នាំឲ្យខ្ញុំសប្បាយចិត្តជាច្រើន ទើបនាំឲ្យខ្ញុំគិតសម្រេចថា ខ្ញុំនឹងចេញទៅក្រុងមើលឆ្ងាយៗ ក្រៅពីកោះតូច-ធំរបស់ខ្ញុំតទៅទៀត ។ ការធ្វើដំណើរជាន់នោះ ខ្ញុំបានឲ្យពាក់ថែងរៀបចំនាវចំនួន ១០ រួចស្រេចក៏បើកក្តោងចេញដំណើរទៅ ។ នាវរបស់យើងបានបើកចេញទៅដោយសុខសប្បាយអស់វេលា ៤០ ថ្ងៃ ឥតមានគ្រោះថ្នាក់អ្វីឡើយ លុះដល់មកយប់គំរប់ ៤១ ថ្ងៃ ទើបមានខ្យល់បក់បញ្ច្រាសមកពីមុខទូក ហើយខ្លាំងក្លាជាព្យុះសង្ឃរាយ៉ាងសំបើម ខឹកស្មានថា នាវទាំងអស់មុខជាលិចលង់ក្នុងជលសា មិនខាន តែលុះដល់ជិតភ្លឺឡើង ខ្យល់ព្យុះនោះក៏សន្សឹមស្ងប់ស្ងាត់បាត់ទៅវិញ មេឃស្រឡះឥតពពក ព្រះអាទិត្យក៏រះឡើងពីទិសបូព៌ា នាវរបស់យើងក៏បានដល់ទៅកោះមួយ ហើយយើងទាំងអស់គ្នាក៏នាំគ្នាចូលចតនាវ ឈប់សម្រាកកំឡាំងនៅកោះនោះអស់វេលាពីរថ្ងៃ ។ រួចយើង

បេះដូងណាក់គេទៅទៀត កាលគន្លងទៅបាន ១០ ថ្ងៃ យើងទឹកសន្សើម ជាខ្ពុះពពុះទឹកបានឃើញ ត្រីយប្រាំងសមុទ្រ នៅត្រង់ណាមួយជាមិនមាន ។ តែដោយហេតុដែលបើចទឹងត្រជាក់ខ្យល់ព្យុះមកប៉ះនោះនាំឲ្យខ្ញុំស្ទើរមិនដឹងខ្លួនណាក៏គេទៅទៀត ទើបខ្ញុំឲ្យវិលមាក់ត្រឡប់ទៅស្រុកវិញ តែតៃកុងរបស់យើងនេះធ្វើផ្លូវ មិនដឹងជាខ្វះវាក្ស៊ិសតំបន់ណា ៗ គង់ថ្ងៃទី ១០ មាក់ឡូមាក់ដែលបានបាត់ឲ្យឡើងដងក្តោងធំនោះ បានស្រែកប្រាប់ពីលើមកថា នៅខាងស្ដាំទិសខាងត្បូងមានតែទឹកទឹងមេឃ ប៉ុន្តែដោកពីខាងមុខនាក់ឃើញមានដុំខ្មៅមួយធំ ។

ឯតៃកុងកាលបានឮមាក់ឡូនិយាយដូច្នោះ ក៏ថ្ងោះទឹកមុខមួយរំពេច ហើយកាំងចះតប់មុខមាត់របស់ខ្លួន ស្រែកឡើងថា "ឱព្រះគុណាថ្ងៃវិសេស យើងតាំងអស់គ្នាមុខជាអន្តរាយជីវិតឥតសល់ដល់ម្នាក់ឡើយ ហើយមូលព្រះបន្ទិជាខ្ញុំក៏គ្មានទព្វាយណាមួយ ទីងជួយព្រះអង្គឲ្យផុតពីគ្រោះថ្នាក់នេះបានឡើយ ។ កាលតៃកុងនិយាយប្រាប់ខ្ញុំដូច្នេះហើយ ក៏តាំងស្រែកទ្រហោយំ ដូចកាល់មនុស្សដែលដឹងខ្លួនថា មុខជាស្លាប់ពិតប្រាកដណាស់ ហើយពួកអ្នកជិះនាវាតាំងប៉ុន្មានក៏ស្រែកយំទ្រហឹងអឹងកង់រំពងកាយគ្នា ។ ខ្ញុំក៏បានសួរអំពីហេតុដែលនាំឲ្យអស់សង្ស័យនោះ តៃកុងក៏បាននិយាយប្រាប់ខ្ញុំថា ខ្យល់ព្យុះធំដែលបក់បោកមកត្រូវនាវាយើងនោះ នាំឲ្យយើងឃ្លាតឆ្ងាយពីផ្លូវរបស់យើងទៅ ដល់ស្នូលវេលា

ថ្ងៃត្រង់ជាក់ យើងនឹងបានឃើញថ្មុំថ្មនោះនៅជិតកែមួង ឯថ្មុំខ្មៅនោះ គឺជាក្អែកខ្មៅៗ ជាមេដែក ដែលកំពុងស្រូបយកដែកនាវារបស់ព្រះករុណាថ្ងៃវិសេស ឲ្យកាន់តែចូលទៅជិតក្អែកនោះជាលំដាប់ ដោយអំណាចដែក គេលទឹងគ្រឿងដែកដែលប្រដាប់នៅនឹងនាវាទាំងនេះ ។ លុះដល់ថ្ងៃស្អែកនេះ វេលាដែលនាវាចូលទៅជិតក្បែរក្អែកនោះ កំឡាំងមេដែកនឹងស្រូបរឹតកាន់តែខ្លាំងឡើង ទាល់តែដែកគោលទាំងអស់បើកចេញទៅជាប់ពីងក្អែក ហើយនាវាទាំងប៉ុន្មានរបស់ព្រះករុណាថ្ងៃវិសេស បែកធ្លាយលិចលង់ក្នុងសមុទ្រអស់ទៅ ។ ដោយហេតុមេដែកមានអំណាចស្រូបយកដែក ហើយមេដែកក៏មានកំឡាំងកាន់តែខ្លាំងឡើង ដោយអំណាចការស្រូបយកដែកផ្សេងៗ មកចុកជាប់នូវច្រើន ហេតុនេះបានជាចំហៀងក្អែកខាងទឹកសមុទ្រ មានដែកគោលច្រើនរាប់គណនាមិនបាន ដែលស្រូបយកមកអំពីនាវាទាំងឡាយ ទើបនាំឲ្យមេដែកនោះ កាន់តែមានកំឡាំងច្រើនឡើងជាអនេក ។ តែក្នុងនិយាយគេទៅទៀតថា ក្អែកនោះចាកពន់ពេកណាស់ នៅលើកំពូលមានមណ្ឌបកងមូល (ដូម) មួយធ្វើពីសម្រិទ្ធយ៉ាងល្អ សសរក៏ធ្វើពីសម្រិទ្ធយ៉ាងល្អដែរ នៅពីក្រោងលើមណ្ឌបនោះ មានរូបសេះសម្រិទ្ធមួយ នៅលើខ្នងសេះមានរូបអ្នកជិះសេះម្នាក់ធ្វើពីសម្រិទ្ធដែរ តែត្រង់ដើមទ្រូងប៉ាំងសំណ នៅទីនៃដែនសំណនោះមានឆ្លាក់យន្តអាគមគាថាផង ។ តែក្នុងនិយាយប្រាប់ខ្ញុំទៀតថា បពិត្រព្រះករុណា

ដ៏វិសេស តាមរឿងក៏តែប៉ុណ្ណោះមកថា រូបនេះឯងជាហេតុបណ្ដាលឲ្យកើតគ្រោះកាចយ៉ាងធំ ដល់ទូកនាក់ទាំងពួកមនុស្សច្រើនជាអនេកដែលមកលិចលង់ក្បាលក្បួយនៅកំបង់នោះ លុះកាលណាមានអ្នកណាមួយ រំលំរូបនោះហោលចេញបាន ទើបលែងមានគ្រោះថ្នាក់អន្តរាយតទៅ” ។

លុះតៃកុងនិយាយដូច្នេះហើយ ក៏តាំងយំសោកតទៅទៀត ពួកអ្នកដំនាក់ទាំងប៉ុន្មាន ក៏នាំគ្នាទ្រហោយំទាំងអស់គ្នា ។ ចំណែកការខ្ញុំក៏ជឿជាក់ថា មុខជានឹងស្លាប់មិនខាន ។ មនុស្សទាំងអស់ក្នុងនាវក៏ប្រមូលខ្លួនទទឹងទទួលនូវមរណៈ ប៉ុន្តែនៅសង្ឃឹមគិតថាក្រែងមានអ្នកខ្លះរស់រួចជីវិតបាន ទើបបបួលគ្នាធ្វើលិខិតដាក់ដៃគ្នាទៅវិញទៅមក គឺធ្វើជាបណ្ដាំប្រគល់មតិកឲ្យដល់គ្នានូវគ្នាបើមានអ្នកណាមួយរស់រួចជីវិតនោះត្រូវបានទទួលសម្បត្តិរបស់អ្នកដែលមរណភាព ធ្វើជាសម្បត្តិរបស់ខ្លួន ។

ដល់ព្រឹកស្អែកឡើង ក៏មើលឃើញភ្នំនោះទាំងអស់គ្នា ឃើញដូច្នេះហើយក៏កើតខ្សឹកខ្សួលឡើងជាថ្មី ដោយមើលទៅឃើញសេចក្ដីស្លាប់កាន់តែច្បាស់ណាស់ ។ លុះពេលថ្ងៃត្រង់ នាវាក៏កាន់តែជិតទៅភ្នំនោះណាស់ មិនយូរប៉ុន្មានក៏ឃើញតាមហេតុដែលតៃកុងនិយាយប្រាប់ គឺដែកគោលទង់ដែកឯទៀតៗ ទាំងប៉ុន្មាន ក៏ហោះចេញពីក្នុងនាវាសំដៅទៅភ្នំនោះទាំងអស់ ដោយកំណាចការស្រូបខ្លាំងក្លាណាស់ ទើបនាំ

ឲ្យត្រូវប៉ះទង្គិចនឹងថ្មយ៉ាងខ្លាំង ។ នាវាទាំងប៉ុន្មានក៏បែកធ្លាយចុះហើយលិចលង់ក្នុងសាគរក្នុងវេលានោះទៅ ។ សមុទ្រត្រង់ណោះក៏ជ្រៅជាពន្លឹក យកប្រដាប់មកល្បងក៏ល្បងមិនដល់ដីផង មនុស្សក្នុងនាវាទាំងប៉ុន្មានក៏លង់ទឹកស្លាប់អស់ ។ ប៉ុន្តែជាកុសលរបស់ខ្ញុំ ព្រះលោកមិនចង់ឲ្យស្លាប់ លោកចង់ឲ្យរួចរស់ជីវិត ក្នុងវេលានោះ ខ្ញុំចាប់បានក្តារមួយបន្ទះមកតោង ហើយមានខ្យល់បក់ផាត់ឲ្យរសាត់អណ្តែតទៅរកដើមភ្នំនោះ ទៅចំត្រង់កន្លែងដែលមានថ្នាក់ សម្រាប់ឡើងទៅដល់កំពូលលើបាន ។

នៅវេលាដែលបានឃើញថ្នាក់ឡើងដូច្នេះហើយ ខ្ញុំក៏តាំងពោលសរសើរគុណព្រះជាម្ចាស់ ដែលបាននាំខ្ញុំមកចំកន្លែងនោះ បើបែរទៅខាងឆ្វេងឬខាងស្តាំនោះ ទីឯមិនមានថ្នាក់សម្រាប់ឡើងសោះឡើយ ហើយខ្ញុំក៏ឡើងតាមថ្នាក់នោះទៅ ។ ដំណើរនោះចោតហើយចង្អៀតលំបាកនឹងឡើងពន់ពេកណាស់ ប្រសិនបើមានខ្យល់យ៉ាងខ្លាំងបក់ផាត់មក ក៏អាចនឹងផាត់យកខ្លួនខ្ញុំឲ្យធ្លាក់ចុះទៅក្នុងសមុទ្រវិញបាន ប៉ុន្តែក្នុងវេលានោះ ខ្ញុំឡើងបានរហូតដល់ទៅកំពូលលើឥតមានគ្រោះថ្នាក់អ្វីឡើយ ខ្ញុំក៏ដើរចូលទៅខាងក្រោមមណ្ឌបនោះហើយ ខ្ញុំលុតជង្គង់ចុះផ្កាប់នឹងដីធ្វើសេចក្តីគារវៈដល់ព្រះជាម្ចាស់ ថ្លែងសេចក្តីសរសើរព្រះគុណដែលបានជួយស្រោចស្រង់ខ្ញុំឲ្យបានរស់រួចជីវិត ។

ក្នុងវេលារាត្រី ដែលខ្ញុំដេកក្រោមមណ្ឌបនោះ ។ នៅវេលាដែលខ្ញុំកំពុងដេកលក់ ខ្ញុំយល់សប្តិឃើញតាចាស់ដែលគួរគោរពម្នាក់ មកឈរពីមុខ ខ្ញុំនិយាយប្រាប់ខ្ញុំថា -- "នែកាប៉ែន, ចូរអ្នកស្តាប់យើង ចាលណាអ្នកភ្ញាក់រលឹកឡើងចូរអ្នកជីកដីក្រោមជើងអ្នកឯង នឹងបានឃើញធ្នូសម្រិទ្ធិ ១ នឹងព្រួញសំណ ៣ ដែលគេបានបនាធ្វើជារូបក្អាយផ្សេងៗ ធ្នូនឹងព្រួញនេះហើយសម្រាប់ស្រោចស្រង់មនុស្សលោក ដែលមានគ្រោះថ្នាក់ដោយសារទឹកទន្លេនេះ ។ ចូរអ្នកឯងយកព្រួញទាំង ៣ បាញ់រូបនេះទៅ ហើយរូបដែលនឹងធ្លាក់ទៅក្នុងសមុទ្រ ហើយសេះនឹងធ្លាក់មកខាងអ្នកឯង ហើយអ្នកឯងកប់វានៅត្រង់កន្លែងដែលអ្នកឯងការយកធ្នូនឹងព្រួញនុះឯង ។ បើធ្វើដូច្នេះហើយ ទឹកសមុទ្រនឹងឡើងខ្ពស់ឡើងរហូតមកដល់ជើងមណ្ឌបនេះ គឺខ្ពស់ស្មើនឹងកំពូលនុះឯង ។ វេលាទឹកឡើងដល់កំរិតនេះ អ្នកនឹងឃើញទូក ១ ចូលដែលមក ទូកនោះមានមនុស្សតែម្នាក់ដែរទេ គាត់ប្រកាន់ចែវទាំងសងខាង ។ មនុស្សនោះក៏ជាសម្រិទ្ធិដែរ ប៉ុន្តែប្លែកផ្សេងពីមនុស្សដែលអ្នកឯងរំលំធ្លាក់មក អ្នកឯងឡើងជិះទូកជាមួយនឹងមនុស្សនោះទៅ តាមតែគេនាំទៅឯណាក៏ដោយ អ្នកឯងកុំនិយាយបញ្ចេញព្រះនាមព្រះជាម្ចាស់ឲ្យសោះ ។ មនុស្សនោះនឹងនាំអ្នកឯងទៅក្នុងកំណត់ ១០ ថ្ងៃ នឹងដល់ទៅសមុទ្រ ១ ផ្សេង ហើយអ្នកឯងនឹងគេនាំចេញវិលទៅស្រុកអ្នកឯងវិញ បានដោយសុខសប្បាយ ប៉ុន្តែត្រូវ

ចាំបណ្ដាំអំពីត្រណម ដែលយើងបានដាក់ទុកនេះឲ្យជាក់ គឺថាក្នុង ១ ដំណើរនេះ ត្រូវអ្នកឯងកុំពោលស្ដីចេញព្រះនាមព្រះជាម្ចាស់ឲ្យសោះ ។

លុះដល់វេលាខ្ញុំភ្ញាក់ឡើង ខ្ញុំមានអំណរនឹងសប្ដិនោះពន់ពេកណាស់ ហើយខ្ញុំក៏ធ្វើតាមបណ្ដាំតាចាស់សព្វគ្រប់ គឺខ្ញុំកាយយកធ្នូនិងព្រួញបានមកហើយ ខ្ញុំក៏បាញ់មនុស្សជិះសេះនោះ រលំធ្លាក់ទៅក្នុងសមុទ្រទៅ ហើយឯសេះរលំចកទាន់ខ្ញុំ ខ្ញុំក៏កាយដីដាក់កប់ត្រង់កន្លែងដែលកប់ធ្នូនិងព្រួញទៅវិញ នៅវេលានោះ ខ្ញុំសង្កេតឃើញទឹកសមុទ្រជោរជន់ឡើងមក រហូតដល់ជើងមណ្ឌបស្ពាន់ទីកំពូលភ្នំនោះ ហើយស្រាប់តែឃើញទូកតូច ១ ពីចម្ងាយចូលជិតមករកខ្ញុំ ក្នុងវេលានោះ ខ្ញុំថ្លែងសេចក្ដីថ្វាយពរសព្ទសាធុការដល់ព្រះជាម្ចាស់ តាមហេតុគេចដែលមានមកតាំងពុំទាន់ប្រាកដត្រូវតាមទំនងរបស់សប្ដិខ្ញុំឥតភ្លៀងចន្លិច ។

នៅទីបំផុត ទូកនោះក៏ចូលអែបមកនឹងកំពូលភ្នំ ហើយខ្ញុំក៏ឃើញមនុស្សស្ពាន់ ដូចតាចាស់និយាយប្រាប់នោះជាយច្បាស់ណាស់ ។ ខ្ញុំក៏ចុះទៅក្នុងទូកនោះទៅ ដោយតាំងចិត្តមិនពោលពាក្យចេញព្រះនាមព្រះជាម្ចាស់ឲ្យសោះ តែពាក្យអ្វីផ្សេងក៏ខ្ញុំតមមិននិយាយដែរ ។ លុះខ្ញុំអង្គុយស៊ប់លើទូកហើយ មនុស្សស្ពាន់ក៏តាំងអុំទូកចេញទៅ បះកែអុំទៅៗ តាំងយប់តាំងថ្ងៃឥតឈប់ឈរសោះ លុះដល់ថ្ងៃទី ៩ ខ្ញុំបានឃើញកោះជាច្រើនដែលនាំឲ្យមានសង្ឃឹមថា ខ្លួនខ្ញុំនឹងផុតពីគ្រោះថ្នាក់ជាដាច់ ។

សេចក្ដីត្រេកអររបស់ខ្ញុំ នាំឲ្យខ្ញុំភ្លេចត្រណមតាចាស់នោះស្រឡះ ហើយខ្ញុំក៏ពោលសរសើរគុណព្រះជាម្ចាស់ឡើងថា ខ្ញុំសូមសរសើរព្រះគុណថ្លៃនៃព្រះអង្គ ខ្ញុំសូមថ្វាយព្រះពរសព្ទសាធុការដល់ព្រះអង្គ ។

ខ្ញុំពោលស្ទើរតែមិនទាន់ផុតពីមាត់ ស្រាប់តែទូកនោះលិចស្រិមទៅក្នុងសមុទ្រជាមួយនឹងមនុស្សស្រម្រិទ្ធនោះទៅ ឯខ្លួនខ្ញុំក៏អណ្ដែតនៅក្នុងទឹក ទំព្រឹងប្រែរប្រែកហែលក្នុងថ្ងៃនោះ ដរាបដល់យប់ងងឹតឈឹងរកមើលទិសតំបន់ពុំឃើញ ទើរតែខំហែលទៅតាមយថាកម្ម ដរាបដល់អស់កំឡាំង ខំប្រឹងហែលស្ទើរតែមិនរួច ខ្ញុំនឹកក្នុងចិត្តថា គង់លង់ទឹកស្លាប់ក្នុងសមុទ្រនោះជាប្រាកដ កំពុងតែគិតអំពីសេចក្ដីស្លាប់ដូច្នេះ ស្រាប់តែរលកយ៉ាងធំប៉ុនភ្នំបោកបក់ជូនខ្ញុំទៅដល់ឆ្នេរខ្សាច់មួយអន្ទើ ហើយខ្ញុំក៏ទើរនៅទីនោះ ៗ វេលានោះ ខ្ញុំក៏ស្ទុះម្នីម្នាឡើងទៅលើគោក ដោយខ្លាចក្រែងមានរលកធំ ៗ មកទាញយកខ្ញុំទៅវិញ ៗ ទៅដល់លើគោកហើយ ខ្ញុំក៏តាំងស្រាកត្រដាងហាលខោអាវលើដីខ្សាច់ ដោយពួតទឹកចេញឲ្យធាប ស្ងួត ព្រោះក្នុងវេលានោះដីខ្សាច់នៅមានចំហាយក្ដៅនៅឡើយ ។

លុះដល់ព្រឹកស្អែកឡើង ខោអាវខ្ញុំក៏ស្ងួតទាំងអស់ ខ្ញុំយកមកស្លៀកពាក់ជាស្រេចហើយក៏ចេញដើរទៅ ដើម្បីពិនិត្យមើលទីឋានឲ្យពីងជាក់ថា ខ្ញុំនៅ ៗ ទីណា ។ ខ្ញុំគ្រាន់តែចេញដើរទៅមួយស្របក់ ក៏ស្រាប់សំគាល់បានថា ទីឋាននោះជាកោះតូច ៗ ឥតមនុស្សនៅ មាន

ដើមឈើផ្លែទំនងព្រៃព្រឹក្សាយ៉ាងស្កុកស្តុក ខ្ញុំបានសង្កេតឃើញថាកោះនោះនៅឆ្ងាយដាច់ស្រឡះពីត្រើយគោកពេកណាស់ នាំឲ្យសេចក្តីត្រេកអររបស់ខ្ញុំថយចុះជាច្រើន ។ ប៉ុន្តែក្នុងវេលានោះ ខ្ញុំបានផ្ទេរសេចក្តីសុខទុក្ខរបស់ខ្ញុំលើព្រះជាម្ចាស់ ក្រោយនោះបន្តិច ស្រាប់តែឃើញទូកក្តោង ១ យ៉ាងតូចបើកក្តោងសំដៅចំមកកោះដែលខ្ញុំនៅ ។

ដោយខ្ញុំជឿជាប្រាកដថា ទូកនោះមុខជាចូលមកចតនៅទីកោះ ហើយដោយខ្ញុំយល់ឃើញថា ពួកមនុស្សជិះទូកទាំងនោះ មិនដឹងជាមិត្តឬជាសត្រូវទេ នោះខ្ញុំពិចារណាយល់ថា គួរកុំបង្ហាញខ្លួនខ្ញុំឲ្យគេឃើញឡើយ ។ ខ្ញុំគិតដូច្នេះហើយ ក៏តាំងប្រញាប់ឡើងដើមឈើយ៉ាងស៊ុំទ្រុម ១ ដើម លាក់ខ្លួនពួនអាត្មាចាំមើលមនុស្សទាំងនុ៎ះឲ្យច្បាស់ ។ វេលាដែលទូកចូលមកចតនៅឆ្នេរខ្សាច់នោះ ឃើញបុរស ១០ នាក់កាន់ប៉ែលជីងគ្រឿងប្រដាប់ជីកដីផ្សេងៗ នាំគ្នាឡើងមកលើគោក ។ មនុស្សទាំងនោះក៏ដើរដង្ហែទៅកណ្តាលកោះហើយឈប់នៅទីកន្លែង ១ ក៏តាំងនាំគ្នាជីកគាស់ដី មួយស្របក់ខ្ញុំមើលទៅឃើញ ហាក់ដូចជានាំគ្នាចាប់លើកគំរប ១ ឡើង ។ រួចពីនោះខ្ញុំឃើញពួកទាំងនុ៎ះ ត្រឡប់ទៅកាន់ទូកម្តងទៀត តាំងនាំគ្នាជញ្ជូនគ្រឿងបរិភោគទំនិញពីក្នុងទូក ខ្លះលីខ្លះសែងឡើងមកកាន់កន្លែងដែលជីកដីនោះ ដល់ហើយក៏ចុះបាត់ទៅក្នុងដីអស់ទៅ ខ្ញុំឃើញដូច្នេះក៏សំគាល់បានថា នៅក្នុងដីមានរូងអ្វីមួយ

យ៉ាងផង ៗ រួចពីនោះខ្ញុំឃើញពួកទាំងនុះត្រឡប់ទៅកាន់ទូកម្តងទៀត ឃើញនាំតាចាស់ម្នាក់និងក្មេងជំទង់ម្នាក់ អាយុប្រហែល ១៤-១៥ ឆ្នាំ រួចក៏ស្អាតបាត់ឡើងទៅកាន់ទីដែល ហើយនាំគ្នាចុះបាត់ទៅ ក្រោយនោះបន្តិចក៏ឃើញចេញពីក្នុងរូងមកវិញទាំងអស់គ្នា ៗ តែវេលាដែលត្រឡប់ទៅចុះទូកវិញនោះ ខ្ញុំសំគាល់ឃើញបាត់ក្មេងជំទង់ មិនឃើញត្រឡប់ទៅទីនេះវិញឡើយ ខ្ញុំនឹកសន្និដ្ឋានថា ក្មេងនោះប្រហែលជានៅក្នុងរូងនោះឯង នេះនាំឲ្យខ្ញុំមានសេចក្តីងឿងឆ្ងល់ឥតគណនា ៗ

តាចាស់និងពួកបារាំងប៉ុន្មាន ក៏នាំគ្នាចុះទូកបើកក្តោងត្រឡប់ទៅវិញ លុះខ្ញុំឃើញទូកនោះទៅឆ្ងាយ ល្មមពួកទាំងនោះមើលមិនឃើញខ្ញុំ ក៏តាំងចិត្តមាចុះពីលើដើមឈើ ហើយដើរសំដៅទៅកាន់ទីដែលគេជីកដីនោះ ៗ ខ្ញុំក៏តាំងកាយដីចេញបានឃើញគំរបមាត់រូងនោះ ទើបខ្ញុំលើកចេញឃើញមានជណ្តើរមួយចុះទៅក្នុងដីជ្រៅពីថ្ម ខ្ញុំក៏ចុះតាមជណ្តើរនោះទៅក៏ជួបនឹងបន្ទប់មួយធំ ឃើញមានកំរាលជើងទីទៃត្រគាប ១ មានក្រាលកម្រាលយ៉ាងល្អ មានខ្នើយកើយខ្នើយគងនិងខ្នើយខ្នបព្រម ហើយឃើញក្មេងនោះអង្គុយកាន់ផ្អែកនៅលើគ្រែនោះ ៗ ខ្ញុំសំគាល់ឃើញវត្ថុតាំងអម្បាលម៉ាន ដោយអំណាចពន្លឺទៀនពីរ ដែលអុជបំភ្លឺក្នុងរូងនោះ ក្មេងនោះឃើញខ្ញុំក៏មានសេចក្តីភិតភ័យ ប៉ុន្តែខ្ញុំស្រែកប្រាប់ទៅវាប្រញាប់ថា "ចូរអ្នកឯង កុំមានសេចក្តីភ័យប្រាមក្តីឲ្យសោះ ៗ

(មានត)

# ប្រវត្តិស្តេចទឹកស្តេចភ្លើង

## ឧកញ៉ាទេពពិទូរ — ក្រសេមរៀបរៀង

(តពីលើកមុន)

អាការនៅរបស់ស្តេចទឹកស្តេចភ្លើងនោះ គឺនៅតែពីរនាក់ត្រមង់ត្រមោចបែបយ៉ាងតាបសបួស គ្មានមនុស្សប្រុសស្រីទៅនៅលាយឡំផងទេ មានមុខការជាអ្នករក្សាព្រះខ័នព្រះរំពាត់ និងគ្រប់គ្រងពួកមនុស្សព្រៃផងគ្នាឲ្យនៅជាសុខ តាមក្បួនកេរ្តិ៍របស់ខ្លួន ៗ

ការរក្សាព្រះខ័ននិងព្រះរំពាត់ៈ អាវុធទាំងពីរនេះ ជារបស់បុរាណតាមដែលគេដំណាលត ៗ មកថា ជារបស់ព្រះមហាក្សត្រខ្មែរដែលទ្រង់ប្រទានទៅស្តេចទឹកស្តេចភ្លើងអង្គដំបូង នៅរក្សានៅគង់ដរាបដល់សព្វថ្ងៃនេះ ។ ព្រះខ័ននោះមានលក្ខណៈដូចម្តេច ក្នុងសម័យនេះគ្មានអ្នកណាដឹងបាន តែគេស្មានថាមានលក្ខណៈមិនសូវជាល្អពិតដូចណាស់ទេ បែបប្រហែលគ្នានឹងព្រះខ័នស្តេចត្រាញ់របស់ខ្មែរយើងប៉ុណ្ណោះឯង ។ ឯព្រះរំពាត់នោះ ជាផ្តៅក្រែកមានចង្កឹះចងរឹបត្រចងាដូចម្តេចខ្លះ គ្មានអ្នកណាដឹងបានជាប្រាកដ ព្រោះតាំងពីព្រះរាជទានទៅស្តេចទឹកស្តេចភ្លើងហើយ ក៏គ្មានអ្នកបានទៅឃើញ ពោះបើមានអ្នកទៅដល់ខ្លះ ក្នុងសម័យក្រោយ ៗ មក ក៏ឃើញតែទាំងរបុំដែលគេរុំទុក ៗ អាវុធទាំងពីរនេះទ្រង់ប្រោសព្រះរាជទានទៅឲ្យជាគ្រឿងយសសម្រាប់អង្គស្តេចទឹ

ស្តេចភ្លើង ជាការផុតផាត់សិទ្ធិខាងអំណាចគាបកាប់សម្លាប់បាន តែបើ យាំងស្តេចត្រាញ់ ដោយហេតុនេះគេទើបមានសេចក្តីគោរព នឹងយកចិត្តទុកដាក់ថែរក្សាដោយគស់អញ តាមដែលកិច្ចយូរ គឺមួយឆ្នាំយូរ ទៅម្ដាយនេះត្រែកបេះរ៉ុំត្រែត (សព្វថ្ងៃនេះ ប្ដូរទៅវត្តប្រយូរវង្ស ឃុំលេខ៤ ក្រុងភ្នំពេញ) ឲ្យការពារ ព្រះខ័នទីងព្រះរំពាត់ៈនោះ គេរុំដោយសំពត់ព្រែពណ៌ក្រហម ព្រះខ័នដាក់ដំកល់លើជើងពាន ១ ព្រះរំពាត់ដាក់លើជើងពាន ១ ដំកល់ទុកនៅក្នុងគុហារបស់ស្តេចទឹកស្តេចភ្លើង ហើយមានជើងពាន ១ ទៀតដាក់ពីខាងមុខ គេតែងបេះផ្លែឈើដែលមាននៅក្នុងព្រៃនោះមកដាក់លើជើងពាននេះ តាមដែលគេនិយាយត ៗ មកថា ផ្លែឈើ ទាំងនេះគេបេះដាក់តែម្ដងក៏នៅស្រស់រហូតមក មិនដែលស្អុយរលួយទៅណា ។ តាមដែលប្រាជ្ញក្នុងព្រះរាជក្រឹត្យថា «នេះសម្រាប់ទីងរុំព្រះខ័នខ្ទូព្រះរំពាត់ ឈូតព្រែក្រហម ៤ ហែងហត្ថ ៩» (សំពត់ព្រែ ២ កំណាត់នេះ គឺ ១ កំណាត់សម្រាប់រុំព្រះខ័ន ១ កំណាត់ទៀត សម្រាប់រុំព្រះរំពាត់) ។ តាមសេចក្តីកត់ហេតុរឿងស្តេចទឹកស្តេចភ្លើងរបស់លោកញូង-សៀងថា ស្តេចភ្លើងមុខងារជាអ្នករក្សាព្រះខ័ន ស្តេចទឹកមានមុខងារជាអ្នករក្សាព្រះរំពាត់ នៅក្នុងភ្នំ ១ ក្នុងស្រុកជ្រាយ ។ អាការដែលស្តេចទឹកស្តេចភ្លើងរក្សាព្រះខ័ននូវព្រះរំពាត់នោះ ប្រហែលគ្នានឹងពួកបាគូរក្សាព្រះខ័នរាជ្យនៅក្នុងព្រះបរមរាជវាំងសព្វថ្ងៃនេះ ។

ការគ្រប់គ្រង៖ តាមជំរឿនប្រជាសាសនាបាយ ដែលតាំងស្តេចទឹក ស្តេចភ្លើងរៀន ដើម្បីឲ្យរក្សាសេចក្តីសុខក្នុងព្រៃទឹកដីរបស់ជាតិអ្នកព្រៃ ទូរជាតិខ្មែរ ជាដំណាក់ព្រះមហាក្សត្រាធិរាជខ្មែរ សមដូចជាសេចក្តីក្នុង ព្រះរាជក្រឹត្យមួយរបស់ថា "ព្រះចៅក្រុងម្ចាស់ត្រាស់លើត្បូងទឹកកញ្ញា-ធិកពិការ ទូរទៅពញាធិកបរិយា ឲ្យនាំព្រះរាជទ្រព្យទៅរាជបណ្ណាការ ផងចេញមកដល់ស្រុក អាយុ៖ អាបា"[១] ប្រសិទ្ធិសំបុកនាមករបរម៉ែទ ពរគួយ ជំរលជំរើងរៀងសន្និបាតឲ្យហៅថា ស្តេចទឹកស្តេចភ្លើង សន្មាតរក្សាព្រះខ័ននៅលើកំពូលភ្នំ ។ ក្តមប្រាកដជាម្ចាស់លើអស់ស្រុក រវើរព្រាយ ពួនតាមគន្លងប្រវេណីអំពីបុរាណរៀង ៗ មកតែងទទឹងតាក់ តែងរក្សាការកែនប្រយ័ត្នផ្សារព្រៃស្រែគេផង ឲ្យដឹងជា-ដឹងការ" ដូច្នេះ យោងអត្ថាធិប្បាយថា អ្នកដែលបានតាំងជាស្តេចទឹកស្តេចភ្លើង ទុកដូចជា គួយរបស់ព្រះមហាក្សត្រាធិរាជ ។ ទុកដូចជាមាក្សិយត្រូវធ្វើការត្រួតត្រា ស្រុកទេសក្នុងផ្នែកនោះជំនួស ដូចយ៉ាងស្តេចត្រាញ់ ការដែលទ្រង់ ព្រះរាជទានព្រះខ័នខ័ង ព្រះរំពាក់ទៅនោះ គឺទ្រង់ព្រះរាជទានអំណាចឲ្យ ចាត់ការត្រួតត្រាតាមគួរទទឹងការ ។ ការត្រួតត្រារបស់ស្តេចទឹកនិងស្តេច ភ្លើងនោះយ៉ាងងាយ ៗ គ្មានអ្វីផ្សារប្រើនណាស់ណាទេ ប្រាកដតាមដែល ចាស់ទុំតាំងឡាយដំណាលមកថា ក្នុងតំបន់និមួយ ៗ ដែលមានប្រជុំជន

---

១ អាយុស អាបាំ នេះប្រហែលជាប្រែថា ស្តេចទឹកស្តេចភ្លើង ។

នៅប្រើន គឺតាំងឈ្មោះអោយធ្វើជានាយកត្រួតត្រា ហៅថា " មេក្រញាញ " ឯមេក្រញាញនេះ មានមុខការត្រួតត្រារក្សាសុខទុក្ខរបស់បណ្ដារាស្ត្រ ដែលនៅក្នុងអំណាចរបស់ខ្លួនកុំឲ្យបំពានពល កុំឲ្យឈ្លោះទាស់ទែងក្នុងពួកគ្នាឯង ឬទាំងពួកដទៃ ទាំងការពារកុំឲ្យពួកដទៃមកបៀតបៀន ឬចាប់យកទៅលក់ ព្រោះអំពីដើមពួកមនុស្សព្រៃនេះច្រើនតែចាប់គ្នាឯងយកទៅលក់ឲ្យខ្មែរ ។ ខ្មែរទិញយកទៅប្រើឲ្យធ្វើការងារនេះសមដូចក្នុងសេចក្ដីកត់ត្រាអំពីរឿងស្រុកខ្មែរ[1] របស់លោក ជាវតាក្វន ថា (ខ្មែរ) គេទិញមនុស្សព្រៃមកប្រើធ្វើការ អ្នកមានធនធានច្រើនមានមនុស្សបម្រើចំនួនច្រើនជាងរយនាក់ក៏មាន ពួកអ្នកដែលមានធនធានតិច ក៏គង់មានពីត្រឹម ១៥ ដល់ ២០ នាក់ក៏មាន វៀរលែងតែអ្នកដែលទាល់ក្រណាស់ ទើបមិនមានខ្ញុំប្រើនឹងគេ ។ ទំនៀមតាំងមេក្រញាញមានដរាបមកដល់សព្វថ្ងៃនេះ, ការត្រួតត្រារបស់ស្ដេចទឹកស្ដេចភ្លើងមានត្រឹមតិចបន្តួចប៉ុណ្ណោះ ។

## ទំនៀមដែលស្ដេចទឹកស្ដេចភ្លើងឡើងស្ដេចខ្មែរ

ទំនៀមពីសម័យខ្មែរបុរាណនោះ ស្ដេចប្រទេសរាជនឹងស្ដេចត្រាញ់កំណត់ឲ្យនាំតង្វាយមាសប្រាក់និងវត្ថុបណ្ណាការមកថ្វាយព្រះមហាក្សត្រាធិរាជនៅក្រុងធំរៀងរាល់ឆ្នាំ គឺក្នុងមួយឆ្នាំម្ដង ចំណែកឯស្ដេចទឹកស្ដេច

---

១ រឿងនេះ យុវនិពន្ធមន្ត្រី ញុក-ថែម ប្រែពីភាសាបារាំងមកជាខ្មែរ មាននៅពុទ្ធសាសនបណ្ឌិត្យ លេខ ក-៥៤ មើលត្រង់ទំព័រ ១១ ។

គ្រឿងរាជបព្វស្ដេចចំណុះដែរ តែការឡើងមានកំណត់ឲ្យយោលជានេះ គឺក្នុង ៣ ឆ្នាំត្រូវឲ្យមកឡើងម្ដង ក្នុងការមកឡើងនេះ គ្មានកំណត់ឲ្យនាំយកអ្វីមកជាតង្វាយបណ្ណាការផងទេ ប្រហែលជាដោយទ្រង់ឃើញថាអ្នកព្រៃនោះសុទ្ធតែជាអ្នកក្រ គ្មានរបស់អ្វីឲ្យជាឧត្តមសមគួរនឹងឲ្យយកមកថ្វាយទេ ឲ្យមកគ្រាន់តែឲ្យបានឃើញមុខគ្នា ដើម្បីសំដែងសេចក្ដីមេត្រីទៅវិញទៅមក ហើយនឹងបានសួរព័ត៌សេចក្ដីសុខទុក្ខក្នុងស្រុកទេសឯណោះជាដូចម្ដេចខ្លះ ដែលគ្រប់គ្រងមក ហើយនឹងឲ្យទូន្មានផ្ដាំបូន្មានខ្លះ ដើម្បីឲ្យមានចិត្តគ្រប់គ្រងស្រុកទេសឲ្យបានសុខស្រួលតទៅ ។ ទោះបីដូច្នោះ វេលាដែលមក, ស្ដេចទឹកស្ដេចភ្លើង ក៏មិនបានមកដៃទទេ រមែងមានរបស់ព្រៃបន្តិចបន្តួចជាបណ្ណាការយកមកថ្វាយរៀងរាល់ដងដែលមក តាមទម្លាប់មកពីព្រេង គឺក្រមួនឃ្មុំត្រាប់ល្អ កុយ ភ្លុក ឆ្អឹងខ្លា ស្បែក ស្លាប សត្វព្រៃ ដ៏ល្អៗចំឡែកៗ ។ របស់ទាំងនេះនៅស្រុកព្រៃសម្បូណ៌ ហើយជារបស់ដ៏សំខាន់ក្នុងស្រុកនេះផង ទើបបាននាំយកមកថ្វាយ តាមដែលមានដូច្នេះ ។ ក្រមួននោះគេធ្វើជាដុំធំៗ ហើយស្ដេចទឹកស្ដេចភ្លើងយកម្រាមដៃបន្តក់ចុះ ឲ្យលេចឃើញលាយលក្ខណ៍ដៃជាសំគាល់ជំនួសបោះហត្ថលេខានឹងបោះត្រា ព្រោះពួកមិនចេះអក្សរនឹងគ្មានត្រាបោះ ។

លុះដល់កាលកំណត់, ស្ដេចទឹកស្ដេចភ្លើងក៏យកគ្រឿងរាជបណ្ណាការ យ៉ាងដែលពោលមកហើយ ឡើងជិះមកកាន់ស្រុកសំបុក ដែលគេកំណត់ទុកជាទ្វារព្រះនគរ ទីនេះជាទីសម្រាប់ទទួលជួបស្ដេចទឹកស្ដេចភ្លើង ។ មកដល់ទ្វារព្រះនគរក៏ឈប់នៅទីនោះ មិនបានចូលមកដល់ក្រុង មិនបានជួបគាល់ព្រះករុណាម្ចាស់ផែនដីទេ ។ មកឡើងក្នុងខែណា ? ថ្ងៃប៉ុន្មានកើតប៉ុន្មានរោច? គេគង់កំណត់មកគ្នាឲ្យដឹងទៅវិញទៅមកជាស្រេចហើយ តែយាត់មកក្នុងវេលានេះមិនសូវមានអ្នកណានឹងចាំបានឲ្យពិតប្រាកដ មានចាស់ទុំដោយប្រែថា មកឡើងក្នុងខែពិសាខ តែនៅថ្ងៃប៉ុន្មានកើតប៉ុន្មានរោចនោះចាំមិនបាន ដោយប្រមាណមើលប្រហែលជាកំណត់មកក្នុងវេរដើមឆ្នាំនៃឆ្នាំទី ៤ គឺដាច់ឆ្នាំទី ៣ ចូលមកក្នុងខែពិសាខនៃឆ្នាំទី ៤ ក្នុងថ្ងៃណាមួយ ក៏ចុះមក ដើម្បីគម្រប់គ្រាវេនពេលឡើងអ្នកតា ព្រោះក្នុងឱកាសនោះមានពិធីឡើងអ្នកតាផង ។

ចំណែកខាងព្រះរាជក្រុងកម្ពុជាធិបតី លុះដល់កាលកំណត់នោះហើយ ទ្រង់តាក់តែងឲ្យមន្ត្រី ២ — ៣ នាក់ជារាជទូតតំណាងព្រះអង្គ ឲ្យនាំយករាជបណ្ណាការដែលសម្រាប់ព្រះរាជទានស្ដេចទឹកស្ដេចភ្លើង ឡើងជិះទៅឯស្រុកសំបុក របស់ដែលសម្រាប់ព្រះរាជទានក្នុងឱកាសនេះមានចំនួនតិចជាងរបស់ដែលព្រះរាជទានក្នុងឱកាសតែងតាំងស្ដេចទឹកស្ដេចភ្លើង តាមទម្លាប់រៀងមក តាមដែលចាស់ទុំទាំងឡាយបានលោកកុំយូរ

(ទឹកញ៉ាំយូរឆ្នាំត្រក) ជាដើម ភ្ជាប់ជូនមកជាសំពត់ផាមួងឬសំពត់ទេសឯក សំពត់ជាតិ កន្ទួយមុខ ២ ក្បិន (មួយក្បិន ១០ ហត្ថ) និងលួសស្ពាន់ (សម្រាប់ធ្វើកងចិញ្ចៀនពាក់) នូវអំបិលជាដើម របស់អំបាលនេះ ត្រូវចែកជា ២ ភាគថ្វាយទៅស្ដេចទឹក ១ ភាគ ទៅស្ដេចភ្លើង ១ ភាគ ។

កាលស្ដេចទឹកស្ដេចភ្លើង និងរាជទូតខ្មែរទៅជួបជុំគ្នាហើយនាំរាជទូតខ្មែរត្រូវចាត់ការធ្វើពិធីឡើងអ្នកតា និងជប់លៀងស្ដេចទឹកស្ដេចភ្លើងជួបមានពេលហើយក៏និយាយពីពិធីតែងតាំងស្ដេចទឹកស្ដេចភ្លើងតាំងដើម ស្រេចកិច្ចជប់លៀងគ្នាហើយ រាជទូតខ្មែរក៏ផ្ដើមនិយាយតាមផ្លូវរាជទូតទៅនឹងស្ដេចទឹកស្ដេចភ្លើង តាមក្បួនទំនៀមការហើយ ក៏ថ្វាយគ្រឿងរាជបណ្ណាការទៅស្ដេចទឹកស្ដេចភ្លើង ឯស្ដេចទឹកស្ដេចភ្លើងក៏យកគ្រឿងរាជបណ្ណាការរបស់ខ្លួនប្រគល់ឲ្យរាជទូតខ្មែរ ឲ្យនាំយកទៅថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង ហើយក៏លាចាកគ្នាទៅ ។ លុះគ្រប់ ៣ ឆ្នាំក៏មកឡើងជួបគ្នាទៀត គ្រប់ៗ ត្រីវស្ស ។

ស្ដេចទឹកស្ដេចភ្លើងតាំងពីបានកំណើតឡើងជាថ្មី ដោយព្រះបាទសម្ដេចព្រះស្រីសុរិយោពណ៌ ទ្រង់ស្ថាបនាឡើងនោះ គេសង្កេតឃើញថា ត្រឡប់រុងរឿងដោយយសសក្ដិអំណាច និងលាភសក្ការៈឡើងវិញជាច្រើន ដោយព្រះមហាក្សត្រទាំងឡាយទ្រង់រក់គាន

ក្នុងពេលដែលគេតាំងឡើងជាថ្មី ឬក្នុងពេលដែលឡើងតាមទេសកាលម្តងៗ នោះទ្រង់ព្រះរាជទានទ្រព្យសម្បត្តិផ្សេងៗ ជាច្រើនណាស់ ដូចមានពោលមកខាងដើម តាំងនេះធ្វើឲ្យស្តេចទឹកស្តេចភ្លើងមានសេរីភាពឡើងវ្រែល តាំងពួកពួនក៏មានសេចក្តីនិយមក្នុងបានជាស្តេចទឹកស្តេចភ្លើងច្រើនឡើង ក្នុងពេលដែលរើសស្នាបនាឡើងជាថ្មីម្តងៗ ខណៈអ្នកស្ម័គ្រទទួលធ្វើដោយសារយ មិនលំបាករើសដូចក្នុងសម័យបច្ចុប្បន្ននេះ តាំងសេចក្តីសម្ពន្ធមេត្រីរវាងខ្មែរនិងពួកជនជាតិគ្នាច្រើន រហូតដល់ទៅពួកពួនពុះចកក្រើយនៅក្នុងចំណោមពួកខ្មែរ ហើយខ្លួនផ្លាស់កេទស្លៀកពាក់តាមសណ្ឋាប់ខ្មែរ ។ ក៏មានច្រើន អ្នកខ្លះបានតាំងធ្វើជាមន្ត្រីក្នុងស្រុកនេះ ដូចយ៉ាងឈ្មោះ យ៉ក ជាដើម ដែលបានធ្វើជាចៅញ៉ាំងគេជា ចៅហ្វាយស្រុក សក្តិ ១០ ហូពាន់ ឈរនៅស្រុកកំពង់ស្វាយ សឹងមានក្បាកដក្នុងពង្សាវតារស្រាប់ ។

ចំណៀមតែងតាំងស្តេចទឹកស្តេចភ្លើង ទំនៀមស្តេចទឹកស្តេចភ្លើងមកឡើងស្តេចខ្មែរនេះ មានរៀងរៀបមកទល់នឹងរជ្ជកាលព្រះបាទសម្តេចព្រះហរិរក្ស (ព្រះអង្គដួង) ទើបដាច់ផកបមកដល់សព្វថ្ងៃនេះ ។ ក្នុងរឿងនេះលោកគគ្គុ យូរ (ឧកញ៉ាយូរ ចៅហ្វាយខេត្តក្រចេះ) បានពិណ៌នាថា ការណែនាំនៅធ្វើចៅហ្វាយខេត្តក្រចេះបានសួរពួកពួនដែលចុះមកក្នុងខែត្រនោះថា ស្តេចទឹកស្តេចភ្លើងដែលរលត់ផែនមក

ទៀតស្ដេចខ្មែរតាំងពីកាលណាមក? ពួកពួនកំបាំងនោះគឺជា តាំងពី
រជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្ស (ព្រះអង្គដួង) មកដោយព្រះកដា
គន្ថនេះទ្រង់បោះបង់ចោលតែម្ដង ។

## ស្ដេចទឹកស្ដេចភ្លើងក្នុងបច្ចុប្បន្ន

សព្វថ្ងៃស្ដេចខ្មែរបោះបង់ចោលដូច្នេះហើយ ស្ដេចទឹកស្ដេចភ្លើងក៏នៅមានគេមកទៀតដកបដល់សព្វថ្ងៃនេះ ការដែលមានគេមកនោះដោយហេតុពួកពួនមានសេចក្ដីគោរពគន់ប្រពៃណីដែលមានមកហើយ អំពីបុរាណ-កាលជាយ៉ាងក្រៃពេក ដូចយ៉ាងព្រះខ័នគេសំគាល់ថាជារបស់សក្ដិសិទ្ធសម្រាប់អ្នកមានបុណ្យជាម្ចាស់លើគេការឥតអំពីស្ដេចទឹកស្ដេចភ្លើងទៅហើយ នឹងបោះបង់ចោលទៅក៏ពុំកើត នឹងលើកឲ្យទៅអ្នកណាមួយក៏ពុំបាន ទើបគេនាំគ្នាបង្កើតឲ្យមានអ្នកតំណាងស្ដេចទឹកស្ដេចភ្លើងមក, តែការរើសខ្លួនជាស្ដេចក្នុងសម័យនេះ តាមដែលពួកពួនតំណាលមកថាជាការលំបាកយ៉ាងក្រៃពេក ព្រោះគ្មានអ្នកណាស្ម័គ្រចិត្តនឹងធ្វើសោះ វេលារើសម្ដង ១ គេរត់បន្ទុំឬគេដេញចាប់ខ្លួនមកសូមគេឲ្យធ្វើទើបបាន, តាមសេចក្ដីកត់ហេតុរបស់លោកញ៉ង-សឿង ក៏ថាដូច្នេះដែរ ។ ការដែលលំ-បាករើសខ្លួនទាំងម្ល៉េះ ក៏ព្រោះការធ្វើក្នុងដំណែងនោះមានមុខការត្រាំងតែជាអ្នករក្សាព្រះខ័នទីងព្រះរំពាត់ គ្មានផលប្រយោជន៍អ្វី គ្មានឫទ្ធិអំណាចឬរួចអំពីដើម នៅត្រឹមត្រូវមោចតែតាំងនាក់កណ្ដាលព្រៃនៃព្រៃ

ពាក់ជួបជាគេយកទៅប្រោសបាល ។ ន័យមួយទៀត គេជឿថាអ្នកដែលបុគ្គលធ្វើជាស្តេចទឹកស្តេចភ្លើងក្នុងសម័យនេះ រមែងដាញ់ខ្លួន គឺសារក្ខ័យទៅស្លាប់, ចំណែកឯស្តេចទឹក នោះគេថាបានក្នុងបុណ្យស្តេចភ្លើងមិនញូវតែ ៤-៥ ឆ្នាំក៏គាត់ស្លាប់, ហេតុតែនេះហើយ ដែលនាំឲ្យពីបាណរើសខ្លួនណាស់ តែដោយហេតុគេកាន់ខ្ជាប់ក្នុងទំនៀមទម្លាប់ដើមក្តាំងពេក ស្តេចទឹកស្តេចភ្លើងមើមនេះឥតយកសាវ មកដល់សព្វថ្ងៃនេះបានក្រោយមិនបានមកឡើងស្តេចខ្មែរដូចពីដើមទេ ។

ចំណែកឯពួកក្រៅស្តេចខ្មែរនៅក្បែរទ្វារព្រះនគរ ដែលធ្លាប់ធ្វើពិធីឡើងអ្នកតាព្រះគង្គព្រះខ័នមកពីដើមដូចម្តេច ក៏មិនហាក់បោះបង់ចោលនៅឡើយធ្វើដរាបមកដល់សព្វថ្ងៃនេះ តាមក្នុងសេចក្តីអត់ហេតុរបស់លោកញ៉ាន-សៀង ថាមានធ្វើរាល់ឆ្នាំ ក្នុងមួយឆ្នាំគេធ្វើពីរដង គឺធ្វើក្នុងខែបុស្ស ឬ ខែមាឃម្តង ក្នុងខែពិសាខ ឬ ខែជេស្ឋម្តង តែការណាតំរប់គ្រាឆ្នាំគេធ្វើពិធីជាពិសេសម្តង ។ ពិធីដែលធ្វើជាជម្ពូគានោះជាពិធីតូចបានកំណត់ដូចនេះ តែកាលណាដល់វេរនោះហើយ ជំទប់អ្នកតាជើរប្រចាំណាអ្នកស្រុកដែលចំណុះអ្នកតានោះ ត្រូវយកគ្រឿងបូជាទៅថ្វាយអ្នកតាតាមថ្ងៃដែលគេកំណត់ទុក តាមទម្លាប់ដែលគេធ្វើមក ក្នុងមួយផ្ទះត្រូវឲ្យមានបាយមួយស្មារ ៣ ខាន់កាំង ១ បាយដំណើប ១ ចាន ទន្ទឹមនឹងអស់គាព្រៃមានស្រាអក ១ ពាង ក្រៅពីនេះ អ្នកដែលត្រូវការសុំពរអ្នកតា

ក៏មានអំបោះសបន្តិចៗ ម្នាក់ៗទៅផង ។ ឯក្បួនបញ្ជាន់រូបសំណាកក្នុងសម័យនេះគ្មានទេ, កាលដល់ពេលជួបជុំគ្នាហើយ គេយកខាន់ស្លា ១ មាន់អាំង ១ បាយដំណើប ១ ចាន យកទៅរៀបដាក់នៅមុខអ្នកតា អ្នកមានអំបោះក៏យកអំបោះដាក់ក្នុងជើងពានយកទៅដាក់ជូន ហើយអុជទៀនធូប នាំគ្នាសែនប្រគេនថ្វាយអ្នកតាទៅ និងសុំពរឲ្យស្រុកទេសសុខសប្បាយ ប្រាសចាកជម្ងឺថ្កាត់សុំឲ្យមានភ្លៀងល្អជាដើម ហើយផ្ដូស្រា-អែកចុះលើគ្រឿងក្រយា អ្នកខ្លះក៏យកដាវមកអុជធូបដាក់ទៀត ប៉ុណ្ណោះឈ្មោះថាស្រេចកិច្ចឡើងអ្នកតានេះហើយ កាលសែនប្រគេនរួចគេក៏ជប់លៀងគ្នាដោយអាហារដែលនាំមករៀងខ្លួន និងស្រាអែកដែលសេសសល់ពីអ្នកតា រួចហើយនាំគ្នាទៅទីលំនៅវិញ យកអំបោះទៅចងកចងដៃឲ្យកូនចៅ ដើម្បីការពារកុំឲ្យឈឺថ្កាត់ ។

វេលាដល់ពេលគំរប់ ៣ ឆ្នាំ គេធ្វើពិធីជម្លូនគ្រប់គ្រឿង របៀបធ្វើនបញ្ជាប ដូចមានពោលមកហើយខាងដើម ប៉ុន្តែមកក្នុងសម័យនេះគ្មានបញ្ជាន់រូបផងទេ ។ ការឡើងអ្នកតានេះ ប្រព្រឹត្តទៅតាមប្រវេណីដែលមានមកហើយពីបុរាណកាល តែមើលទៅឃើញហាក់ដូចជាតំណាងការដែលស្ដេចទឹកស្ដេចភ្លើងមកឡើងស្ដេចខ្មែរពីដើម ។

សំដែងមកក្នុងប្រវត្តិស្ដេចទឹកស្ដេចភ្លើងចប់តែប៉ុណ្ណោះ ។

# នារាយណ៍ទសាវតារ

ឧកញ៉ាទេពពិទូរ - ក្រសេម ហៀចហៀង

(តមកនិងចប់)

អ្នកឥតគ្នាសក៏កេណ្ឌយកព្រះពុទ្ធទៅជាព្រះអវតារទី ៩ របស់ខ្លួន ដើម្បីឲ្យមនុស្សប្រុះចូលរួមជាមួយគ្នា តែតាមសេចក្ដីពិតនោះគឺព្រះពុទ្ធមិនបានជាព្រះអវតាររបស់ពួកនេះក៏ទេ ។

កល្ក្យាវតារ មិនមានមកក្នុងកលិយុគ តាមពាក្យទំនាយថា មានរូបជាបុរសជិះសេះស ដើម្បីកាចកម្ទេចមនុស្សអាក្រក់បានទូទៅទាំងលោក និងបណ្ដាលឲ្យមនុស្សមានសត្យធម៌ក្នុងលោកឡើងវិញ ដូចការបកកតយុគ, ដោតម្ការសាថែនសេចក្ដីសង្ឃឹមទៅក្នុងអនាគត ដូចយ៉ាងពួកពុទ្ធសាសនិកជនដែលប្រាថ្នាឲ្យជួបនឹងព្រះសិអារ្យមេត្រៃយ ។

ព្រះនាមរបស់ព្រះនារាយណ៍មានចំនួនរាប់ពាន់ ហៅតាមឫទ្ធិតេជះ និងតាមហេតុការណ៍ដែលជាសេចក្ដីបេសារិមាន គេកាន់ថា អ្នកណាទន្ទេញចាំបានអស់ទាំងឈ្មោះបុណ្យ គឺៈ ១-បញ្ចាវុធ = កាន់ ៥ យ៉ាង, ២-នារាយណ៍ = នៅក្រោមក្នុងទឹក, ៣-បុរស = ប្រុស, ៤-អច្យុត = មិនចេះច្រឡំយលោក, ៥.អនន្ត = គ្មានទីបំផុត, ៦-ហរិ = សូនក្យា, ៧-គោវិន្ទ ឬគោបាល = រក្សាផែនដី, ៨-អនន្តសៃយានៈ = ដេកលើនាគអនន្ត-

នាគរាជ, ៩ - ចតុភុជ = ដៃបួន, ១០ - គរុឌាសន = អ្នកគ្រងនៅលើខ្នងគ្រុឌ, ១១ - ឆារេព = កើតរំលំមកព្រោះផ្ទៃមហាសមុទ្រកយំ, ១២ - ហ្ឫសិកេស = ជាម្ចាស់នៃរបស់ដែលធ្វើឲ្យកើតសេចក្ដីសុខ, ១៣ - ជលសាយិន = ដេកលើទឹក, ១៤ កុមុទ = អ្នកដំណួរ, ១៥ - បទ្មនាភ = ផ្ចិតជាឈូក, ១៦ - បិតម្ពរ = ស្លៀកលឿង, ១៧ - មធុសូទន = អ្នកសម្លាប់មធុ គឺអសុរដែលព្យាយាមប្រទូសរ៉ាយព្រះព្រហ្មដែលកើតក្នុងផ្កាឈូក សង្គ្រោះឡើងអំពីនាភីព្រះអង្គ, ១៨ កិរីតិន = អ្នកទ្រង់គ្រឿងប្រដាប់ប្រដាក្បាល, ១៩ - ត្រិវិក្រម = ឈាន ៣ ជំហាន, ២០ - លក្ស្មណាបតិ = ប្ដីព្រះលក្ស្មី, ២១ - ជនាទ្ទន = អ្នកដែលជនពប់អាន, ២២ - នរ = មនុស្ស, ២៣ - វាសុទេវ = បុត្រព្រះវាសុទេព, ២៤ - បុរុសោត្តម = ទេវរាជ, ២៥ - យញ្ញេស្វរ = ម្ចាស់នៃយញ្ញកម្ម, ២៦ - វៃកុណ្ឋនាថ = ជាធំក្នុងវៃកុណ្ឋ, ២៧ - ចតុរ្ពាហុ = ដៃបួន, ២៨ - កេសព (កេសវ) = មានសក់ក្រាស់ឬសក់ល្អ, ២៩ - ស្រីករ = ដៃមានសិរី, ៣០ - ស្រីសំខករ = ដៃកាន់សង្ខដ៏មានសិរី, ៣១ - វិណ្ហុប្រិស្ន ..., ៣២ - គុន្ធីស = អ្នកជាធំជាងគេ។ល។ ស្រាវជ្រាវមកបានតែប៉ុណ្ណេះ ។

ព្រះលក្ស្មី (សក្តិ (sakti) ផង ជាយាព្រះនារាយណ៍ មានកំណើតមកអំពីក្សីរសមុទ្រ ក្នុងកាលដែលកួរសមុទ្រទឹកដោះក្នុងរឿងកូម៌ាវតារ, ក្នុងទីខ្លះពោលថា នាងជាធីតាឫសីភ្រុគុ ដែលជាសង្ឃ្យកដក្នុងយុគព្រះវេទនឹងធីតាព្រះទក្ស១, មានឈ្មោះហៅផ្សេង១ គឺលោកទេវី = ទេវីរបស់លោក

លោកមាតា = មាតារបស់លោក, ជាអ្នកទ្រង់នូវសិរីរូបដ៏ល្អ ជាស្នេហ៍ ជាទេវី នៃសេចក្ដីស្រឡាញ់គឺជាកាមទេព ដូចកាលព្រះនាងផុះឡើងអំពីក្អែកក្សីរសមុទ្រ ពួកទេវតានឹងអសុរឃើញក៏កើតសេចក្ដីស្នេហាខ្លាំងក្រៃខ្លួន ពួកអសុរញាញ់ញីលេងដោយរូបពោមនាង ទើបមិនបានទឹកអម្រឹតផឹក ។ ព្រះស្វាមី ជាពាក្យប្រែ នាងជាពាក្យនិយាយ, ព្រះវិស្ណុជាអ្នកកាត់សេចក្ដី នាងជាអ្នកអង្គុយស្រុំ, នាងជាផែនដី ព្រះនារាយណ៍ជាអ្នកទ្រទ្រង់ផែនដី, នាងជាទេពនារីអំណោយលោក មានព្រះហឫទ័យប្រកបដោយមេត្តាករុណាជានិច្ច ភាពហៅជាស្នេហ៍នូវឲ្យក្រៃពេក នាងទ្រទ្រង់ដោយគុណសម្បត្តិ ដូច្នេះ ទើបបាននាមជាគន្ធើ ជាអ្នកទ្រទ្រង់ស្រីគ្រប់ជាតិ ។ រូបភាពនេះច្រើនធ្វើជារូបស្រីសម្បុរមាស ដៃបួនក៏មាន ដៃពីរក៏មាន ចំណាំតែឈរលើផ្កាឈូករីក នៅចន្លោះរូបដំរីពីរ ដំរីនោះព្រួសទឹកលើសិរនាង មួយមិនដូច្នោះ កំណាស់ផ្កាឈូក, បើជារូបម្នាក់ឯង តែងខ្លួនពេញយស សិរប្រដាប់ដោយទេពគ្រឿង ដៃកាន់ផ្កាបទុម មានអន្ទាក់សម្រាប់ទាក់ មានសំបកគ្រុំសម្រាប់ៈ ។ នៅស្រុកជ្វា នាងក្លាយទៅជាព្រះព្រៃស្រពណ៍ ជាអ្នកឲ្យកំណើតស្រូវដល់ពួកកសិករ ដៃធ្វេងកាន់នូវស្រូវ ដៃស្ដាំធ្វើគ្រឿងសំគាល់នៃសេចក្ដីមេត្តាករុណា ។

ព្រះលក្ស្មីជាគូនឹងព្រះនារាយណ៍ មិនសូវដែលឃ្លាត បានតាមស្ដេចអវតារមកកាន់ច្រើនគ្រាគឺ កុងកុមារីតារ នាងកើតក្នុងក្សីរសមុទ្រ

ទើបបាននាមថាក្សីរាព្ធិតនយា កូនស្រីរបស់ក្សីរសមុទ្រ ឬជលធិជា កើតអំពីទឹក, ក្នុងកម្មនាវតារ នាងចុះមកកើតក្នុងផ្កាឈូក ទើបមាននាមថា បទ្មា ឬកមលា; ក្នុងបរសុរាមាវតារ នាងជានាងធរណី, ក្នុងរាមចន្ទ្រាវតារ នាងជានាងសីតា, ក្នុងក្រឹស្ណាវតារ នាងជានាងរុក្មិណី; ហេតុនេះគេអាចនឹងឃើញបានថា គ្រប់គ្រាដែលមកកើតរមែងជាទេវីស្រឡាញ់របស់ព្រះអវតារទាំងអស់, ក្រៅអំពីនេះនៅមាននាមថា ឥន្ទិរា, កញ្ចក់ឬលោកមាតាជាដើម ។

ក្នុងទីខ្លះពោលថា ព្រះវិស្ណុមានមហេសី ៣ អង្គ គឺព្រះសរស្វតី, ព្រះគង្គា ព្រះស្រី (លក្ស្មី); នាងទាំង ៣ នេះមានសក្តិស្មើគ្នា ជាធំរៀងខ្លួន មិនបេះញីមអ្នកណាឡើយ, ចំណាំតែតមរឿងឲ្យក្តៅក្រហាយដល់ព្រះវិស្ណុញយៗ ទើបទ្រង់គោរលះព្រះសរស្វតីឲ្យទៅព្រះព្រហ្ម ព្រះគង្គាឲ្យទៅព្រះសិវៈ ព្រះអង្គឯងនៅសល់តែព្រះលក្ស្មីមួយ, តម្រាខ្លះពោលថា ព្រះធរណី (ភូមិទេវី) ក៏ជាជាយារបស់ព្រះអង្គដែរ ។

អាវុធ = ព្រះនារាយណ៍ទ្រង់អាវុធ ៥ យ៉ាងគឺ ១ សង្ខឈ្មោះបញ្ចជន្យ, ២ - ចក្រឈ្មោះសុទស្សនៈ ឬវជ្រនាភៈ, ៣ - គទា (ដំបង) ឈ្មោះកោមោទកី, ៤ - ធ្នូឈ្មោះសារ្ងគៈ, ៥ - ដាវឈ្មោះនន្ទកៈ ។

រូបព្រះវិស្ណុដែលគេសាងឡើងច្រើនធ្វើដៃ ៤ ហើយកាន់សង្ខ, ចក្រ, គទានិងផ្កាឈូក នៅទ្រូងមានកេស គេដូចជាអន្តស្រីវត្សៈ មានស្លាប់ច្រើន ឈ្មោះកៅស្តុភ មានវល័យ (គង) ធ្វើជាប់ដោយត្បូង សយមន្តកៈ ។

វៃកុណ្ឋ = ឋានសួគ៌ដែលព្រះវិស្ណុទ្រង់សណ្ឋិតនៅឈ្មោះ វៃកុណ្ឋ, គេនិយមហាការតពោលថាផែនដីនោះជាមាសទាំងមែន, មានបរិមណ្ឌល ហាសិបម៉ឺនយោជន៍ វិមានប្រដាប់ដោយកែវមណី សសរ ទីក្រៀនប្រដាប់វិមាននេះធ្វើដោយកែវពេជ្រ ទឹកព្រះគង្គាធារហូរ ពីឋានសួគ៌ជាន់ខ្ពស់បំផុតមកពីលើសិរសា (ផ្កាយធ្រុវ) ហូរចេញពីនេះ ធ្លាក់មកលើព្រះចន្ទ្រ រួចទាំងប្រាំពីរ (គឺផ្កាយទាំង ៧ ដែលហៅថា ផ្កាយក្រពើ) ហើយហូរចុះមកដល់ភពផែនដី; ឋានសួគ៌ដ៏ស្រស់ល្អនេះ នៅលើកំពូលភ្នំព្រះសុមេរុ ដែលតាំងនៅកណ្ដាលកោះជម្ពូទ្វីបកណ្ដាល ផ្កាឈូក ដែលត្រងបាលោក, មើលពីកំពូលភ្នំព្រះសុមេរុ ក៏ទើបឃើញ ផ្កាឈូក ៤ ក្លីប បាញ់ញរស្មីព្រាតទៅជុំវិញ, សត្វទាំងអស់ក្បែរដីកំជុំ វិញ ព្រះសុមេរុនេះដែលជាដែនកើតទេវតាលើឋានសួគ៌មានស្រះថ្ម ស្រះនានាពេញទៅដោយទឹកស្អាតថ្លាមេឃ. ក្រហម, ស, លើបណ្ដុំផ្កាដែល ... ព្រះជួបព្រះនាងទេព្យកន្លោមមហាស្ត្រីកាកា (ថ្ងៃត្រង់) ព្រះ វិស្ណុគង់លើអាសនៈឈូក មានព្រះលក្ស្មីស្ថិតនៅខាងស្ដាំ ... ... ... ទីទំមានក្លិនចេញពាក្យព្រះទេវី ត្រកូលនោះទៅរហូតពីរយោជន៍ ។

ស្តេចក្រុង ក្រុងជាតាបោទះរបស់ព្រះវិស្ណុ ជាទាសព្រះកស្សបះ ព្រះបាទពីង តាទិនតា ដោយហេតុនាងនេះការកទទួលនាងកក្រុមជា

មហេសីស្ដាំរបស់ព្រះកស្សបៈ ហៅថាមាតានៃនាគទាំងឡាយ, នាងកទ្រូយកឈ្មោះហៅយុបាយ ពួកនាគដែលជាសត្វនៅក្នុងមហាសមុទ្រជន់ផឹកទឹកអម្រឹតនឹងគេដែរ ទើបគិតបោកថាដិវៃទ្យខ្លួននាងវិនតា ដែបាក់ស្ដេចគ្រុឌមកដណ្ដើមបោកទឹកអម្រឹតទៅ ។

ព្រះកស្សបៈ មានមហេសី ២ អង្គ គឺនាងកទ្រូនឹងនាងវិនតា, មុនដែលព្រះព្រហ្មនឹងសាងលោក បានប្រទានបុត្រតាមដែលនាងទាំងពីរប្រាថ្នា ដែនាងកទ្រូលោភលន់ខ្លាំងណាស់ បានសុំបុត្រដល់ពាន់នាក់ នាងវិនតាសុំត្រឹម ២ នាក់ប៉ុណ្ណោះ តែនាងបានសុំឲ្យបុត្រទាំងពីរមានបុណ្យជាងបុត្រនាងកទ្រូ, កាលនាងទាំងពីរប្រសូតទារសមក ក៏មានលក្ខណៈខុសពីសាមញ្ញជន គឺជាពង[១] ដូចនាងសិការបស់ក្រុក, កន្ទុំអតាំត្រេចរបកតែ (បកៈណៈរបស់ពួកហ៊ាក្ខពាក់ជាវេលារយៈ ១ឆ្នាំ) ពងរបស់កទ្រូក៏ញាស់ចេញមកជាប្រុសៗ ចំនួនមួយពាន់ តែពងរបស់នាងវិនតាមិនឃើញហេតុថានឹងញាស់ឡើយ នាងប្រាថ្នានឹងប្រកួតដោយបុត្ររបស់ត្រូវដោយឆាប់ៗ ទើបបោះពងមួយឲ្យបែក ក៏ឃើញជាសត្វដែលមិនសម្បូណ៌ជាអលក្ខណៈ ពោលគឺមានតែត្រឹមពាក់កណ្ដាលខ្លួនហៅថាអរុណ ។ មានសេចក្ដីអៀនខ្មាស់ឧទិរាងកាយរបស់ខ្លួន

---

១ ក្នុងទី១ៈគោលថាតាងទិតិមាតានៃអាប្បសៈប្រស្សុតិជាពង ទើបញាស់ចេញមកជាស្ដេចគ្រុឌ ។

ហើយដាក់បណ្ដាសាថា នាងកទ្រុបានបង្ខំនាងវិនតាជាទាសី, លុះកាលខ្លួនមកប្រមាណ ៥ ជួរកាយុ ស្ដេចគ្រុឌក៏ញាស់អំពីពងទីពីរ ដើម្បីស្រោចកិត្តិយសនៃមាតាឡើងវិញ . បានតស៊ូនឹងបុត្រនាងកទ្រុពាល់តែមានជ័យ, សាហេតុនេះឯងហើយ ដែលបណ្ដាលឲ្យគ្រុឌនិងនាគមិនចេះត្រូវគ្នា ។

គម្ពីរខ្លះពោលថា សាហេតុដែលគ្រុឌនិងនាគតាំងឡាយអរិទិនគ្នា ព្រោះនាងវិនតានិងនាងកទ្រុកែកគ្នាដោយរឿងពណ៌សម្បុរសេះ ដែលទ័ពរថព្រះអាទិត្យ នាងកទ្រុថាសម្បុរខ្មៅ នាងវិនតាថាសម្បុរក្រហម ហើយកើតភ្នាល់គ្នាថា បើអ្នកណាចាញ់ត្រូវធ្វើខ្លួនជាខ្ញុំរបស់អ្នកឈ្នះ នាងកទ្រុធ្វើឧបាយប្រើកូននាគដែលជាបុត្ររបស់ខ្លួន ឲ្យទៅព្រួសឲ្យសេះព្រះអាទិត្យមានពណ៌ខ្មៅ នាង ចាប់ឈ្នះជ័យជំនះក្នុងការភ្នាល់ នាងវិនតាក៏ធ្លាក់ទៅជាខ្ញុំរបស់នាងកទ្រុ ពួកនាគបុត្រនាងកទ្រុទារទឹកអម្រឹតជាថ្លៃខ្លួន តែស្ដេចគ្រុឌដណ្ដើមយកទៅមុន ព្រះឥន្ទ្រហោះតាមមកដណ្ដើមបានច្បាំងនឹងគ្រុឌកដ តែក៏ចាញ់ប្រែះធ្លាក់បែក ទេវត្ថុផលព្រះវិស្ណុចុះមកក្រោមក៏មិនសម្រេច គម្ពីរខ្លះក៏ព្រមធ្វើសម្ពន្ធមិត្រនឹងគ្នា មានសេចក្ដីថា លោកអង្គព្រះវិស្ណុសុខចិត្តឲ្យគ្រុឌនៅខ្ពស់ជាង តែវេលាទៅណាមកណាត្រូវជិះគ្រុឌ, គ្រុឌកដនេះមានលក្ខណៈមុខសត្វ ខ្លួនដូចមនុស្សសម្បុរមាស មានស្លាប ២ សំពត់ក្រហម

មានក្របកដូចសត្វភ្នំយ៉ាងប្រពន្ធឈ្មោះនន្ទគិរីវាយកា មានបុត្រ ឈ្មោះសម្បាតិ មាលាយាស់ៗ ដូចយ៉ាងកស្សប, វេនតេយ្យ, គរុឌ-ទាន, បន្នគាសនៈ (អ្នកក្រមាំងនាគ) វិហង្គរាជ, សុបេក្ខដ៏ង, ខគេន្ទ្រៈ (ស្ដេចនៃបក្សី), សុបណ្ណ, ប្រជិត ទាំងនេះនៅមាននាមយ៉ាងដទៃទៀត ជាច្រើនតាមគុណសម្បត្តិនឹងតាមហេតុការណ៍នោះៗ មានវិមាននៅជា វិមាន ហៅថាសិម្ពលីតែនៅជើងភ្នំកាត់ខ្នែមហាសមុទ្រ ។

ក្នុងវត្ថុះពោលថា សុបណ្ណកជនេះជាកូននាងវិនតា, គ្រាមួយនោះ នាងវិនតាចាញ់គេ ធ្លាក់ទៅជាទាសីរបស់កទ្រូសៈមិនអាចនឹងរួចខ្លួន ចេញបាន ឯកបណ្ណាតែនាងជួយឲ្យខ្សល់បកទឹកអម្រឹតឲ្យខ្លាក់ចេញរបស់ព្រះ ព្រះសុមេរុដែលឡោមដោយភ្នំនរកើង ត្រូវកដ៏ភិតនិងជួយមាតា ទើប ដំណែងខ្លួនឲ្យតូចកូតទៅក្នុងបន្ទះភ្នំនរកើង ទៅប្រមូលទឹកស្ដេចនាគ ពីរ ក្នុងក្រហមដូចភ្លើង ត្រូវកដ៏ណាស់ស្មាប់ឲ្យចូលចូលក្នុង ហើយ សម្លាប់ ហើយទើបចាក់អនក្រានទឹកអម្រឹតហើររត់ទៅ ពួកទេវតាឃើញ ដូច្នោះ ក៏ដេញតាមព្រះឥន្ទ្រច្រានបណ្ណាលឲ្យផ្ទុះឃ្មាញ់ តែគ្មានណាក់ សាប់ដល់តិបឡើយ ត្រាន់តែមានរោមមួយជ្រុះមកប៉ុណ្ណោះ, កាលបាន ទឹកអម្រឹតទៅឲ្យកទ្រូស: នាងវិនតាក៏បានជាផុតស្រឡះភាពដូចដើម, មុន ដែលអសុរនឹងផឹកអម្រឹតនេះ ព្រះឥន្ទ្រក៏មកកញ្ចក់យកតែងផ្នាំនោះហោះ ទៅឯឋានសួគ៌ ពួកនាគបានតែលិទ្ធស្មៅនៅទីដែលត្រូវដាក់តែងថ្នាំទិព្វ

ស្តេចក៏លះអណ្តាតនាគជាច់ជាចំរៀត ។ ។ តមកគ្រុឌក៏បានជាពាហនៈ របស់ព្រះវិស្ណុ ហោះហើរលឿនដូចខ្យល់មានវិមានដ៏ល្អជាទីអាស្រ័យ នៅ ហៅថា សិម្ពលី ប្រែថា ដើមរកា គឺអាស្រ័យនៅនឹងដើមរកាជា វិមាន ។

គ្រុឌនេះជាស្តេចលើពួកបក្សីសត្វទាំងពួង នៅស្រុកខ្មែរអំពីដើម គេជឿនឿនក៏រគ្រុឌ ដោយល្អិតល្អបញ្ចាស់លាស់ណាស់ ទើបបានមាន សាងរូបគ្រុឌទុកនៅព្រះពជ័យខ្ទីរទឹងទៅតាមប្រាសាទបុរាណជាច្រើន ថែបច្រើនយ៉ាងណាស់ មានរូបគ្រុឌចាក់នាគជាដើម អ្នកចង់ឃើញ គួរតែទៅមើលឯប្រាសាទអង្គរ ។

នាគពង: នាគស័ព្ទនេះ តាមដែលធ្លាប់ប្រែមកហើយថា ពស់ ថា ពស់ស៊ីមានលក្ខណៈរូបកន្ទៃ ១ ដូចយ៉ាងពស់ តែបានស៊ីដូចយ៉ាង មាន់, លោកចំណែកទុកជា ៤ ពួកគឺ: ១ នាគសុគន្ធមានមុខងារជាអ្នកក្សា វិមានវេរា, ២ នាគអាកាសមានមុខងារជាអ្នកបណ្ដាលឲ្យភ្លៀងធ្លាក់ មក, ៣- នាគលោកបាល មានមុខងារជាអ្នកក្សាសមុទ្រទន្លេ, ៤- នាគ ក្សាកំណប់ទ្រព្យ មានមុខងារជាអ្នកក្សាទ្រព្យដែលគេកប់ទុកក្នុងដី ។ ពពួកនាគ: គេលថាមានច្រើនពួក ជាអ្នកក្សាកំណប់ទ្រព្យដែល មានកន្ទិតកក្រោមដី, មានទីលំនៅ ១ តាមសមុទ្រ - ទន្លេ តែទីលំនៅ ពិសេស គឺបាតាល ជាលោកមួយនៅក្រោមផែនដី មានពង់ពានី

ឈ្មោះភគវតី ហៅថា ស្កុកស្កម ប្រាកដតាមគម្ពីរវិរុឡ្ហកៈ ទីផ ចន្ទុប្បកៈ ជាលោកគុរុអាចារ្យមានប្រែនកាន់ ក្នុងគម្ពីរ វាចា សេចក្តីសុខសប្បាយហាក់ដូចបានស្គាល់ នៅឯនគរក្លែងត្រៈទីងមានពាក់ផល ជាតម្បូរព្រះគម្ពីរ ខ្ពស់នាងទិត ត្រូវត្រង់នៅកំព្រែងជាន់ ។

ក្នុងពួកនាគនេះ មានពួកជាត្រូវត្រង់ហើយគេអោយឈ្មោះថា ស្តេចលើពួកសត្វទាំងពួងផង នាគរាជដែលជាធំបំផុតក្បាលប្រុង បំពេញគប: ថែមយ៉ាំងយោគីតាល់តែព្រះព្រហ្ម ប្រចាំនគរទៀត ម៉ាកនេះ ទៅបូជាសេសនាគក់ដុះ ហើយមានដំរីស៊ីសំរាប់យាត្រូវកំប្ បើមហា ឈ្មោះថា ឥន្ទ្រ មានក្បាល ៧ ក្នុងទីខ្ពស់ជាមានស្រាលរាប់ពាន់ ជា បញ្ចក្ខរស្រោមមុំរបស់ព្រះវិរូឡ្ហកក្នុងកប្បវិនាស ។

រឿងកំរែស្តេចនាគនោះមានច្រើនណាស់ នៅទីនេះតែប្រចាំតាមនាម ទៀង ច្រើនបែបច្រើនយ៉ាងស្មើតែងមានកម្ពុជាគោលពុំបាន ក្នុងត្រៃបិដក នាគរាជក៏ធ្លាក់ជាខ្សែបាននគរការរបស់ព្រះបាទសក្យព្រហ្ម, ក្នុងព្រះពុទ្ធការ ធ្លាក់ជាខ្សែពាញក្លាសមុទ្រទំនោរ បានព្រួសពិសជាភ្លើងប្រល័យកល្ប ដែលលាងលោកក្នុងកាលកប្បវិនាស រាប់ជាខ្លួនរាំមួយគាថាទីងនាគរាជ ឈ្មោះ មុចលិន្ទ បានតាមព្រះនាងយកភ័ពមកកើតក្នុងមនុស្សលោកដូច ហើយកើតជាព្រះលក្ខណ៍ក្នុងអវតារត្រាទី ៧ នឹងជាព្រះពលទេពក្នុង

"សតវត្សទី ៨ ក្នុងស្រុកពុកាគោក៏មាននាគកដមកទាក់ទងនឹងផាច្រើន ផង ដូចជាក៏ស្ដុបលិទ្ធនាគកដជាដើម ។

នាគពោះបីមានតិសកំណាចក៏ពិត តែក្នុងរឿងខ្លះមានរឿងរ៉ាវថា នាគជាក្រុមចិត្តបុណ្យ ឈើផ្កាលដល់មនុស្សដែលមានសេចក្ដីករុណាប្រណី ដល់នាគ, នាគបំណាំ ក៏តំណោយសតិបញ្ញា ដែលជារបស់មិនអាចមើល ឃើញបាន, ឯនាងនាគី ឬ នាគិនីក៏ដូចជានាងអប្សរ ជាសត្វគួរឲ្យស្នេហា ពុលចិត្តសម្ពន្ធនឹងមនុស្សរហូតដល់ទៅយកមនុស្សទៅយកធ្វើជាស្វាមី ខាង មនុស្សក៏ពូលចិត្តនិយមនាងនាគណាស់ដែរ ដូចមានប្រាកដក្នុងរឿងរ៉ាវ ផ្សេង ៗ ជាច្រើន សូម្បីក្នុងព្រះរាជពង្សាវតារខ្មែរយើងក៏ថា ព្រះថោងនឹង ព្រះចម្រើនពកជា ឬនព្រះមហេសីជានាងនាគ រហូតដល់ទៅពង្សាវតារ ចិន -ចេន- ណាដែលជាដើមក៏ពោលតៅយទំនងដូចគ្នានេះ ។

ខ្មែរយើងក្នុងជាន់ដើម រហូតមកដល់សម័យទំនើប គេធ្លាប់ដឹង រឿងរ៉ាវនាគកដនេះ ដោយល្អិតល្អមណាស់ហើយ គេនិយមជាសត្វវិសេស ព ពាំងដូរពោលមក ទើបបានសាងរូបនាគនៅប្រាសាទបុរាណ មានចំនួន រាប់ម៉ឺនរាប់សែន រឿងក្នុងស្រាក្ដួរសម្ភុទ្ធចុះកដោះក៏មាន ក្នុងគ្រាប្រល័យ-កល្ប ព្រះវិស្ណុជំលើសេសនាគកដក៏មាន សាងជានាគត្រាបោល ថែម ពោធិ៍ជានស្នងក៏មានជាច្រើនអនេក អ្នកប្រាថ្នាចង់ឃើញ សូមអញ្ជើញ ទៅពិនិត្យមើលចុះ ។

អវសាន

ម៉ក្លាទិក្ខកថា

ឃុនសុវត្ថិរេទ័យប្រ.គុន រៀបរៀង

ជមត្ត រគជក្ខយ ស្រ្ត

សូមនមស្សការចំពោះព្រះរតនត្រ័យ

# សេចក្ដីផ្សេងគ្នានៃការយល់ឃើញ

មនុស្សក្នុងលោកសន្និវាសនេះ មិនថាជាតិណា សាសន៍ណាទេ តែងតែមានសេចក្ដីយល់ឃើញ ដែលហៅថា ទិដ្ឋិ ផ្សេងៗគ្នាជាច្រើនប្រការ តែបណ្ដាសេចក្ដីយល់ឃើញទាំងនោះ ការយល់ឃើញខ្លះ ក៏សមហេតុសមផល, ការយល់ឃើញខ្លះ ក៏ឃ្លាំងមិនត្រូវចំនងមិនសម បែបបៀបធ្វើយកមិនបាន. កុំថាតែមនុស្សក្នុងសម័យឥឡូវនេះ ដែលជាមនុស្សធ្លាក់នៅក្នុងផង់ធាត់មានអាយុថយតិចចុះ ទាំងប្រាជ្ញាសំរាប់ជាគិត ក៏មានស្ដួចស្ដើងនេះទៀយ សូម្បីក្នុងសម័យពុទ្ធកាល គឺសម័យដែលព្រះសម្ពុទ្ធទ្រង់គង់ធរមានទៅទៀត ក៏មានមនុស្សច្រើនពួកដែលមានសេចក្ដីយល់ឃើញ ទិន្នសេចក្ដីប្រកាន់ ខុសពីលទ្ធិពុទ្ធសាសនា ដូចយ៉ាងគ្រូ ៦ នាក់[១] មានគ្រូឈ្មោះបូរណកស្សបៈជាដើម គេយល់

១ បូរណកស្សបៈ ១ មក្ខលិគោសាល ១ និគណ្ឋនាដបុត្ត ១ សញ្ជយវេលដ្ឋបុត្ត ១ បកុធកច្ចាយនៈ ១ អជិតកេសកម្ពល ។ គ្រូទាំង ៦ នេះ ជាមនុស្សមិច្ឆាទិដ្ឋិ ជាមនុស្សអន្ធពាលទេ តែប្ដេជ្ញាខ្លួនជាព្រះសម្ពុទ្ធ ។

ឃើញថា "ធ្វើអំពើអាក្រក់មានការសម្លាប់សត្វជាដើម ឈ្មោះថាមិនធ្វើបាប" ទេយល់ឃើញសត្វដែលស្លាប់ទៅកើតក៏សៅហ្មងឯង ឬ សត្វដែលទទួលបរិសុទ្ធក៏បរិសុទ្ធឯង មិនមែនមានហេតុបច្ច័យណាមួយនាំឲ្យសៅហ្មង ឬ នាំឲ្យបរិសុទ្ធឡើយ" យ៉ាងនេះជាដើម ។

ហេតុនោះ ទិដ្ឋិការយល់ឃើញនេះ បើនឹងសង្កេតពីខាងការទោស គុណ ដោយស្មើៗនឹងវិញ្ញូជនទាំងទេ, ក៏ឃើញថាមិនឲ្យទោសធ្ងន់ឲ្យគុណផលដល់អ្នកយល់ឃើញប៉ុន្មានឡើយ, តែបើពិចារណាឲ្យល្អិតជ្រាលជ្រៅហើយ ក៏គង់ឃើញថាទិដ្ឋិនេះ ជាធម៌ដែលមានកំឡាំងខ្លាំងបំផុត អាចដឹកនាំមនុស្សឲ្យមានសភាពប្រព្រឹត្តត្រឹមត្រូវតាមធម៌ក៏បាន. ឲ្យប្រព្រឹត្តធ្វើអំពើអាក្រក់ដែលមានទោសស្រាលខ្លះ ធ្ងន់ខ្លះក៏បាន ទាំងជាធម៌ដែលអាចបណ្ដាលបញ្ចូលពួកកុសលធម៌ ក៏ដូចអកុសលធម៌ដែលឲ្យរីកចម្រើនឡើងក្នុងសន្ដានចិត្តអ្នកយល់ឃើញនោះៗក៏បាន ដូចទិដ្ឋិរបស់បរិព្វាជក ៣ នាក់គឺ. ។

## រឿងសញ្ជ័យ (1)

សេចក្ដីថា ក្នុងក្រុងរាជគ្រឹះ មានបរិព្វាជក ៣ នាក់ គឺសញ្ជ័យបរិព្វាជក ១ ឧបតិស្សបរិព្វាជក ១ (2) កោលិតបរិព្វាជក ១ (3) បណ្ដាប-

---

១ រឿងនេះមានសេចក្ដីពិស្ដារក្នុងគម្ពីរធម្មបទដ្ឋកថា ភាគ ១ ត្រង់យមកវគ្គ ។ ២ កាលកើតមកបួសក្នុងពុទ្ធសាសនា គេហៅថា "សារីបុត្ត" ព្រោះជាកូននាងសារីព្រាហ្មណី ។ ៣ គេហៅថា "មោគ្គល្លាន" ព្រោះជាកូននៃនាងមោគ្គល្លីព្រាហ្មណី ។

ព្វាជកទាំង ៣ នាក់នេះ សញ្ជយបរិព្វាជកជាមហាគណាចារ្យ មានសិស្ស កប់រយនាក់, ឯឧបតិស្សបរិព្វាជកនឹងកោលិតបរិព្វាជក ត្រូវជាសិស្សរបស់សញ្ជយបរិព្វាជកនោះ តែជាអ្នកមានទិដ្ឋិយល់ត្រូវ, បានលះបង់ទិដ្ឋិគេចោល ដោយយល់ឃើញថាមិនមែនជាមោក្ខធម៌ ។ ឧបតិស្សបរិព្វាជកបានស្ដាប់អរិយសច្ចកថាសង្ខេបអំពីសំណាក់អស្សជិត្ថេរ ក៏បានសម្រេចសោតាបត្តិផល ហើយនាំដំណឹងនោះមកប្រាប់ដល់កោលិតបរិព្វាជកជាសំឡាញ់ ។ បានស្ដាប់ហើយក៏បានសម្រេចសោតាបត្តិផលដូចគ្នា ទើបនាំគ្នាទៅបបួលសញ្ជយបរិព្វាជកដែលជាគ្រូខ្លួន ឲ្យចូលទៅគាល់ព្រះសាស្ដាក្នុងវត្តវេឡុវ័ន ដោយហេតុតែគាត់ជាមនុស្សមានទិដ្ឋិយល់ខុស ក៏មិនព្រមទៅ ។ បរិព្វាជកទាំង ២ នាក់បាននាំបរិវាររបស់ខ្លួនទៅសូមបព្វជ្ជាឧបសម្បទាក្នុងសំណាក់ព្រះសម្ពុទ្ធ មិនយូរប៉ុន្មានក៏បានសម្រេចអរហត្តផល ព្រមទាំងតាំងនៅក្នុងទីជាអគ្គសាវក ។ រឿងនេះ បណ្ឌិតគួរប្រាប់ថា ឧបតិស្សបរិព្វាជកនឹងកោលិតបរិព្វាជក ដែលបានសម្រេចអរហត្តផល ព្រមទាំងបានដំណែងដ៏ប្រសើរនេះក៏ព្រោះទិដ្ឋិ (១) សញ្ជយបរិព្វាជក ដែលធ្លាក់ខ្លួនក្នុងទីជាមនុស្សអន្ធពាលក៏ព្រោះទិដ្ឋិ (២) ហេតុនោះបានជាព្រះភគវាជាគ្រូនៃយើងទ្រង់ត្រាស់ថា :

១ សំដៅយកសម្មាទិដ្ឋិ ។ ២ សំដៅយកមិច្ឆាទិដ្ឋិ ។

អសារេ សារមតិនោ សារេ ច អសារទស្សិនោ

តេ សារំ នាធិគច្ឆន្តិ មិច្ឆាសង្កប្បគោចរា

សារញ្ច សារតោ ញត្វា អសារញ្ច អសារតោ

តេ សារំ អធិគច្ឆន្តិ សម្មាសង្កប្បគោចរា

សេចក្តីថា ជនទាំងឡាយឯណា យល់ឃើញក្នុងធម៌ឥតខ្លឹម(១) ថាជាធម៌មានខ្លឹម(២)វិញ យល់ឃើញក្នុងធម៌មានខ្លឹមថាជាធម៌ឥតខ្លឹមវិញ ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្តីត្រិះរិះខុសជាអារម្មណ៍ រមែងមិនបាននូវធម៌មានខ្លឹម(៣) ជនទាំងឡាយឯណា សំគាល់នូវធម៌មានខ្លឹមថាជាធម៌មានខ្លឹមផង សំគាល់នូវធម៌មិនមានខ្លឹមថាជាធម៌មិនមានខ្លឹមផង ជនទាំងឡាយនោះ ឈ្មោះថាមានសេចក្តីត្រិះរិះត្រូវជាអារម្មណ៍ រមែងបាននូវធម៌មានខ្លឹម ។

សេចក្តីដែលបានថាហើយមកប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញច្បាស់ថាទិដ្ឋិនេះ ជាបហាតព្វធម៌ គឺធម៌ដែលគួរលះបង់ចេញក៏មាន ជាភាវេតព្វធម៌ គឺធម៌ដែលត្រូវសន្សំឲ្យកើតក្នុងសន្តានក៏មាន ។

ទិដ្ឋិបែបណាជាបហាតព្វធម៌? ទិដ្ឋិបែបណាជាភាវេតព្វធម៌? មុននឹង

---

១ មិច្ឆាទិដ្ឋិមានវត្ថុ ១០ ធម៌ទេសនាជាហេតុឲ្យកើតមិច្ឆាទិដ្ឋិ នេះហៅថាធម៌ឥតខ្លឹម ។ ២ សម្មាទិដ្ឋិមានវត្ថុ ១០, ធម៌ទេសនាជាហេតុឲ្យកើតសម្មាទិដ្ឋិ នេះហៅថាធម៌មានខ្លឹម ។ ៣ សីល, សមាធិ បញ្ញា, វិមុត្តិ, វិមុត្តិញ្ញាណ, ទស្សន, រួមជា ៦ នេះក៏លោកហៅថា ធម៌មានខ្លឹមដែរ ។

ដោះប្រស្នានេះ ទាំងសូមពណ៌នាអំពីទិដ្ឋិសព្ទ ឲ្យឃើញគោលសេចក្តី ជាមុនសិន ។ សព្ទថា "ទិដ្ឋិ" នេះប្រែថា "សេចក្តីយល់ឃើញ" ប្រើជាពាក្យកណ្តាលៗ មិនសំគាល់ថាការយល់ខុស ឬជាការយល់ត្រូវ យ៉ាងណាមួយនៅឡើយទេ; ដែលទាំងឲ្យដឹងច្បាស់ថាសព្ទនេះ ត្រូវប្រែថា "ការយល់ខុស" ឬ "ការយល់ត្រូវ" នោះ គប្បីអាស្រ័យសព្ទជាគ្រឿងសំគាល់ ២ យ៉ាងគឺ "មិច្ឆា" និង "សម្មា" ដែលលោកប្រកបទុកនៅខាងដើម ទិដ្ឋិសព្ទៈជាអធិសមាស សម្រេចរូបជា មិច្ឆាទិដ្ឋិ សម្មា-ទិដ្ឋិ ។ មិច្ឆាទិដ្ឋិសព្ទ ប្រែថា "សេចក្តីយល់ឃើញខុស" សម្មាទិដ្ឋិសព្ទ ប្រែថា "សេចក្តីយល់ឃើញត្រូវ" ។ តែក្នុងបាលីភាសាច្រើនប្រើ "ទិដ្ឋិ" សព្ទនេះជាគ្រឿងសំគាល់ខាងសេចក្តីយល់ឃើញខុសដោយមិនបាច់យក មិច្ឆាសព្ទ មកប្រកបចូលផង ដូច ទិដ្ឋិសម្បន្នោ "អ្នកដល់ព្រមដោយទិដ្ឋិ" ទិដ្ឋិវិបន្នោ "អ្នកវិបត្តិព្រោះទិដ្ឋិ" ដូច្នេះក៏មាន សព្ទទាំងពីរនេះ ក៏គង់ជាគ្រឿងសំគាល់ឲ្យដឹងថា "អ្នកដល់ព្រមដោយមិច្ឆាទិដ្ឋិ" "អ្នកវិបត្តិព្រោះមិច្ឆាទិដ្ឋិ" ។

ទិដ្ឋិនេះ បើនិយាយដោយសេចក្តីផ្សេងគ្នានៃការយល់ខុស និងការយល់ត្រូវ ដូចពោលមកខាងលើនោះចាត់ជា ២ ប្រការគឺ មិច្ឆាទិដ្ឋិ=សេចក្តីយល់ឃើញខុស១ សម្មាទិដ្ឋិ= សេចក្តីយល់ឃើញត្រូវ១ ។ បណ្តាទិដ្ឋិទាំង២ប្រការនេះ មិច្ឆាទិដ្ឋិ ជាបឋមាគតធម៌ គឺជាទិដ្ឋិដែលគួរលះ

បង់បោលចេញអំពីខន្ធសន្តានៈ ព្រោះមិច្ឆាទិដ្ឋិនេះជាប្រធាននៃអកុសលធម៌ទាំងពួង ទាំងជាធម៌មានទោសធ្ងន់បំផុតក្រៃពេកជាងអកុសលឯទៀត ឯសម្មាទិដ្ឋិ ជាភាវេតព្វធម៌ គឺជាទិដ្ឋិដែលគួរអប់រំបំប៉នទុកក្នុងខ្លួន ឬគួរពន្យល់បណ្តុះក្នុងចិត្តឲ្យកើតមានឡើង ព្រោះសម្មាទិដ្ឋិនេះជាប្រធាននៃកុសលធម៌ទាំងពួង ។ កើតឡើងបានក៏អាស្រ័យតែទិដ្ឋិនេះ ។

តអំពីនេះទៅ នឹងអធិប្បាយចំពោះតែមិច្ឆាទិដ្ឋិមួយក្នុងកន្លែងសៀវភៅក្បាលនេះ តាមន័យដែលមានមកក្នុងគម្ពីរទាំងពីរក្បាល មានគម្ពីរមង្គលត្ថទីបនី អដ្ឋកថាមង្គលសូត្រជាដើម ។

## មិច្ឆាទិដ្ឋិ

ពាក្យថា មិច្ឆាទិដ្ឋិនេះ ប្រែថាយ៉ាងណា ? មានសេចក្តីអធិប្បាយដូចម្តេច ? ។

ពាក្យថា មិច្ឆា ប្រែថា "ខុស" ទិដ្ឋិ ប្រែថា "ការយល់ឃើញ" ប្រែរួមទាំងពីរសព្ទថា "ការយល់ឃើញខុស" ៖ បានសេចក្តីថា គំនិតដែលគេយល់ឃើញមិនត្រូវតាមទំនងនៃធម៌ ឬមិនសមតាមហេតុផលដែលពិតប្រាកដហៅថា "មិច្ឆាទិដ្ឋិ" មានបទវិគ្គហៈក្នុងដីកាវិសុទ្ធិ ឬត្រថា អយាថាវគ្គហណាការេន មិច្ឆា បស្សតីតិ មិច្ឆាទិដ្ឋិ (ប្រែថា) ធម្មជាតិឯណាឃើញខុស ព្រោះមិនកាន់យកតាមសភាពដែលពិត ធម្មជាតិនោះឈ្មោះថា មិច្ឆាទិដ្ឋិ, នេះជាសេចក្តីប្រែតាមរូបសព្ទ មិច្ឆាទិដ្ឋិ ។

មានសេចក្តីអធិប្បាយថា ឧបាទិន្នកសង្ខារ គឺសង្ខារដែលមាន វិញ្ញាណគ្រប់គ្រង សូម្បីមានភេទផ្សេង ៗ គ្នាយ៉ាងណាក៏ដោយ ក៏គង់ធ្លាក់ចុះក្នុងគន្លងនៃលក្ខណៈ ៣ យ៉ាងដូចគ្នា, មែនពិតបន្ទាសង្ខារទាំងពួង កាលបើតាំងឡើងហើយ មិនដែលរួចផុតចាកលក្ខណៈ ៣ យ៉ាងឡើយ រមែងមានលក្ខណៈ ៣ យ៉ាង គេប្រចាំជាធម្មតា, ឯលក្ខណៈ ៣ យ៉ាង នោះគឺ អនិច្ចលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាមិនទៀង ១, ទុក្ខលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាជាទុក្ខ ១, អនត្តលក្ខណៈ ហេតុជាគ្រឿងសំគាល់ថាមិនមែនជារបស់ខ្លួន ១ ។ សេចក្តីកើតឡើងក្នុងខាងដើម, សេចក្តីប្រែប្រួលទៅក្នុងកណ្តាល, សេចក្តីបែកធ្លាយទៅវិញក្នុងទីបំផុត នេះជាគ្រឿងសំគាល់ថាមិនទៀង ហៅថាអនិច្ចលក្ខណៈ ការអត់ធន់ចំពោះសេចក្តីលំបាកព្រោះការឈឺចាប់ ដើម្បានដោយកម្រ នេះជាគ្រឿងសំគាល់ថាជាទុក្ខ ហៅថា ទុក្ខលក្ខណៈ; ការប្រព្រឹត្តទៅផ្សេង ៗ នៃខន្ធមិនត្រូវតាមអំណាចខ្លួន ដូចសក់ស្កូវជាដើម គេមិនត្រូវការឲ្យស្កូវឲ្យបាក់ ក៏គង់តែស្កូវនឹងតែបាក់ទៅបាន នេះជាគ្រឿងសំគាល់ថាមិនមែនជារបស់ខ្លួន ហៅជា អនត្តលក្ខណៈ ។ បើបុគ្គលឯណា ពិចារណាឃើញសង្ខារ ដែលមានលក្ខណៈ ៣ យ៉ាង នៅប្រចាំជាធម្មតានោះ ថាមិនមានលក្ខណៈ ៣ ប្រការដូច្នេះក្តី, ឬក៏ពិចារណាឃើញសង្ខារដែលមិនទៀង ថាទៀងវិញ ដែលជាទុក្ខ ថាជាសុខវិញ ដែលមិនមែនជារបស់ខ្លួន ថាជារបស់ខ្លួនវិញ

ដូច្នេះក៏ ការយល់ឃើញរបស់បុគ្គលនោះ ហៅថា មិច្ឆាទិដ្ឋិ ព្រោះយល់ឃើញខុសចំពីគន្លងដែលពិតមែន ។ ម្យ៉ាងទៀត ក្នុងគម្ពីរអដ្ឋសាលិនីថា: មិច្ឆាទិដ្ឋិសហគតេន (ចិត្តេន) ខន្ទសិកាទយោ សេដ្ឋាតិ គេសំ អភិវាទនអញ្ជលិកម្មកុហបឋកចរិកណ្ហាទីនិ ករោតិ (សេចក្តីថា) បុគ្គលឯណាពិតាណាឃើញវិបរិតដោយចិត្តគិតខុសថា "ទេវតាតាំងឡាយមានខន្ធកុមារនិងព្រះឥស្វរជាដើមជាបុគ្គលប្រសើរបំផុតក្នុងលោក" ដូច្នេះហើយធ្វើនូវការបូជាមានអភិវាទនកម្មគឺអំពើដែលប្រណម្យកាយថ្វាយខ្លួនលុតជង្គង់ថ្វាយបង្គំ និងអញ្ជលីកម្ម គឺអំពើដែលធ្វើនូវក្រពុំម្រាមដៃលើកឡើងប្រណម្យនមស្ការ ចំពោះទេវតាតាំងឡាយមានខន្ធកុមារ និងព្រះឥស្វរជាដើមនោះឬធ្វើនូវគ្រឿងតាំងសម្រាប់បូជាផល់រូប ក្នុងក្បួនទីនេះ ប្រោះព្រំដោយគ្រឿងសក្ការបូជាមានគោម័យជាដើម, ការចូលចិត្តខុសហើយធ្វើកិច្ចយ៉ាងនេះក៏ឈ្មោះថា មិច្ឆាទិដ្ឋិ ។ សូម្បីសេចក្តីយល់ឃើញរបស់បុគ្គលឯណាថា "សត្វដែលបានទៅកើតក្នុងសុគតិឬទុគ្គតិបានសោយសេចក្តីសុខឬទុក្ខ មិនមែនកើតមកអំពីផលនៃកម្មដែលខ្លួនធ្វើល្អនិងអាក្រក់ទេ គឺកើតមកអំពីសំណាក់នៃទេវតាមានខន្ធកុមារនិងព្រះឥស្វរជាដើម ទេវតាពួកនេះឯងជាអ្នកប្រគល់ឲ្យនូវសេចក្តីសុខ និងទុក្ខដល់ពួកសត្វ"; សេចក្តីយល់ឃើញរបស់បុគ្គលនោះ ក៏ហៅថា មិច្ឆាទិដ្ឋិ, នេះជាសេចក្តីអធិប្បាយនៃពាក្យថា មិច្ឆាទិដ្ឋិ ។

(មានត)

# កែតម្រូវ

ពាក្យថា "ព្រះស្រីសុរិយោព័ណ៌" ចំនួនប៉ុន្មានអន្លើ ក្នុងប្រវត្តិស្ដេចទឹកស្ដេចភ្លើង ដែលមានចុះផ្សាយក្នុងសៀវភៅកម្ពុជសុរិយា លេខ ១១-១២ ប្រចាំខែណូវែម្ប្រ៍-ដេសែម្ប្រ៍ ១៩៦៥ ត្រូវកែថា "ព្រះស្រីសុរិយោព័ន្ធ" វិញ និងពាក្យថា "...ឲ្យជាក់ជាង" ក្នុងសៀវភៅ លេខ ១១ ខែណូវែម្ប្រ៍ ១៩៦៥ ត្រង់រឿងអធិប្បាយសុភាសិតខ្មែរ ទំព័រ ៧០០ បន្ទាត់ ១៥ ត្រូវកែថា "...ឲ្យជាក់ជ្រីង" ដូច្នេះវិញ ។